# អេស៊ីលីដា ត្រេននីង សេនធ័រ

ថ្នាលបណ្តុះបណ្តាលដែលលោកអ្នកជឿទុកចិត្ត




# របាយការណ៍ប្រចាំឆ្នាំ

# ២០១៤

# វគ្គសិក្សាភាសាអង់គ្លេសទូទៅ

## General English Program

វគ្គសិក្សាភាសាអង់គ្លេសទូទៅ គឺជាកម្មវិធីបណ្តុះបណ្តាលភាសាអង់គ្លេសទូទៅមួយ ដែលមានលក្ខណពិសេសគ្មាននៅក្នុងកម្មវិធីបង្រៀនតាមសាលារៀនទូទៅ ត្រូវបានរៀបចំឡើងយ៉ាងផ្ចិតផ្ចង់ដោយអេស៊ីលីដា ត្រេននីង សេនធ័រ សម្រាប់កម្មករនិយោជិតធនាគារ អេស៊ីលីដា និងបុត្រសម្ព័ន្ធ និស្សិត ព្រមទាំងសាធារណជន ដើម្បីធ្វើឲ្យប្រសើរឡើងលើចំណេះដឹង នៃភាសាអង់គ្លេសរបស់អ្នកសិក្សា ដែលនៅមានកម្រិត ប្រកបដោយគុណភាព វិន័យ និងក្រមសីលធម៌វិជ្ជាជីវៈ តាមរយៈលំហាត់សិក្សា ទាំងការនិយាយ ការស្តាប់ ការអាន ការសរសេរ និងការអភិវឌ្ឍវាក្យស័ព្ទ ។

វគ្គសិក្សាគ្រប់កម្រិត បង្រៀនដោយគ្រូបរទេសដើមកំណើតនិយាយភាសាអង់គ្លេស រួមជាមួយគ្រូបង្រៀនជនជាតិខ្មែរ ដែលមានជំនាញគរុកោសល្យ និងបទពិសោធន៍បង្រៀនច្បាស់លាស់ ។



# ទស្សនៈ និងបេសកកម្ម

## ទស្សនៈ

អេស៊ីលីដា ត្រេននីង សេនធ័រ ជាមជ្ឈមណ្ឌលឈានមុខក្នុងប្រទេសកម្ពុជា ក្នុងការផ្តល់សេវាកម្មបណ្តុះបណ្តាលវិស័យធនាគារ និងហិរញ្ញវត្ថុ ប្រកបដោយគុណភាពខ្ពស់បំផុត ជូនដល់សិក្ខាកាមទាំងក្នុង និងក្រៅប្រទេស ។

## បេសកកម្ម

បេសកកម្មរបស់ អេស៊ីលីដា ត្រេននីង សេនធ័រ គឺបណ្តុះបណ្តាលសិក្ខាកាមទាំងក្នុង និងក្រៅប្រទេសនូវចំណេះជំនាញធុរកិច្ច ធនាគារ និងហិរញ្ញវត្ថុទាន់សម័យ ប្រកបដោយគុណភាពខ្ពស់បំផុត ដើម្បីអភិវឌ្ឍសមត្ថភាពក្នុងការគ្រប់គ្រងចាត់ចែងអាជីវកម្មឱ្យមានប្រសិទ្ធភាព ដោយអនុវត្តឱ្យបាននូវនិរន្តរភាព និងបង្កើនអត្ថប្រយោជន៍ជូនដល់ភាគទុនិក កម្មករនិយោជិត ព្រមទាំងសហគមន៍ទាំងអស់ ។

យើងប្រកាន់ខ្ជាប់ជានិច្ចនូវគោលការណ៍សីលធម៌វិជ្ជាជីវៈ សង្គម ច្បាប់ និងបរិស្ថាន ប្រកបដោយកម្រិតខ្ពស់បំផុត ។




របាយការណ៍នេះរៀបចំដោយ
ការិយាល័យទំនាក់ទំនងសាធារណៈ
និងគណៈកម្មាធិការប្រតិបត្តិ
អេស៊ីលីដា ត្រេននីង សេនធ័រ និង
ចេញផ្សាយដោយការិយាល័យទំនាក់ទំនងសាធារណៈ ។



សម្រាប់ព័ត៌មានបន្ថែម និងចម្ងល់ផ្សេងៗ
សូមទាក់ទងមក អេស៊ីលីដា ត្រេននីង សេនធ័រ
អាសយដ្ឋាន៖ អគារលេខ៥០ ផ្លូវលេខ៥១៦ កែង៣៣៥
ភូមិ០៦ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា ។

ប្រអប់សំបុត្រលេខ ៖ ១១៤៩
ទូរស័ព្ទ ៖ ០២៣ ៩៩៩ ៩៤៤ / ៨៨១ ៧៩០
ទូរសារ ៖ ០២៣ ៩៩៩ ៩៧៩ / ៨៨១ ៧៨០
អ៊ីម៉ែល ៖ info@acledatrainingcenter.com.kh
គេហទំព័រ ៖ www.acledatrainingcenter.com.kh

# កម្មវិធីបណ្តុះបណ្តាលរបស់ អេស៊ីលីដា ត្រេននីង សេនធ័រ

## កម្មវិធីបណ្តុះបណ្តាលសម្រាប់ស្ថាប័នខាងក្រៅ និងសាធារណជន

អេស៊ីលីដា ត្រេននីង សេនធ័រ ផ្តល់នូវការហ្វឹកហ្វឺនផ្សេងៗពីគ្នា ដែលគួបផ្សំចំណេះដឹង និងជំនាញ ក្នុងការអនុវត្តការងារដោយផ្តោតលើគុណភាពជាចម្បង ។ បច្ចុប្បន្ននេះ អេស៊ីលីដា ត្រេននីង សេនធ័រ មានកម្មវិធីហ្វឹកហ្វឺន៧ប្រភេទ ផ្តល់ជូនអតិថិជនមកពីស្ថាប័នខាងក្រៅទាំងក្នុងប្រទេស និងអន្តរជាតិ ៖



១- វគ្គហ្វឹកហ្វឺនតាមប្រក្រតិទិនហ្វឹកហ្វឺនប្រចាំឆ្នាំ



២- វគ្គហ្វឹកហ្វឺនតាមតម្រូវការ ឬតាមការស្នើសុំ



៣- វគ្គទស្សនកិច្ចសិក្សា សម្រាប់ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ




៤- វគ្គសិក្ខាសាលា និងទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ សម្រាប់និយតករមីក្រូហិរញ្ញវត្ថុ



៥- វគ្គហ្វឹកហ្វឺនអភិវឌ្ឍន៍ជំនាញ សម្រាប់និស្សិត និងសាធារណជន



៦- វគ្គហ្វឹកហាត់ការងារជាក់ស្តែងនៅកន្លែងការងារ





៧- វគ្គសិក្សាភាសាអង់គ្លេសទូទៅ

## កម្មវិធីបណ្តុះបណ្តាលសម្រាប់កម្មករនិយោជិត ធនាគារ អេស៊ីលីដា ភីអិលស៊ី

អេស៊ីលីដា ត្រេននីង សេនធ័រ បានបំពេញមុខងារដ៏សំខាន់ផងដែរក្នុងការបណ្តុះបណ្តាលសមត្ថភាពកម្មករនិយោជិត ដែលបានរួមចំណែកនៅក្នុងភាពជោគជ័យរបស់ ធនាគារ អេស៊ីលីដា ភីអិលស៊ី ។ បច្ចុប្បន្ននេះ អេស៊ីលីដា ត្រេននីង សេនធ័រ មានកម្មវិធីហ្វឹកហ្វឺន៣ប្រភេទសម្រាប់បណ្តុះបណ្តាលកម្មករនិយោជិត ធនាគារ អេស៊ីលីដា ភីអិលស៊ី ៖



១- វគ្គហ្វឹកហ្វឺនកម្មករនិយោជិតថ្មី




២- វគ្គហ្វឹកហ្វឺនការងារដំបូង



៣- វគ្គបណ្តុះបណ្តាលកម្មករនិយោជិតដែលកំពុងបម្រើការងារ (វគ្គបំពាក់បំប៉ន និងវគ្គសិក្ខាសាលាបណ្តុះបណ្តាលជំនាញគ្រូហ្វឹកហ្វឺន)

# ទិន្នន័យហិរញ្ញវត្ថុសង្ខេប

| ឯកតាគិតជាដុល្លារអាមេរិក | ៣១/១២/១៤ បានធ្វើសវនកម្ម | ៣១/១២/១៣ បានធ្វើសវនកម្ម | ៣១/១២/១២ បានធ្វើសវនកម្ម | បម្រែបម្រួល (%)[១] |
|---|---|---|---|---|
| **ទិន្នន័យហិរញ្ញវត្ថុសង្ខេប** | | | | |
| ទ្រព្យសកម្ម | ១៦.៥២០.៣១៦ | ៣.០៤៩.៧៥៤ | ១.៧៦៤.៧៣៦ | ៤៤១% |
| បំណុល | ៧៤០.៩៣០ | ៧៤១.៩៨៨ | ៧២៤.៩៩២ | 0% |
| ដើមទុន | ១២.៨០៥.000 | ២០៥.000 | ២០៥.000 | ៦.១៤៦% |
| មូលនិធិម្ចាស់ហ៊ុន | ១៥.៧៧៩.៣៨៦ | ២.៣០៧.៧៦៦ | ១.០៣៩.៧៤៤ | ៥៨៣% |
| ចំណូលដុល | ៣.៥៤១.៨៨៦ | ៣.៦១៧.២៣៣ | ២.៦៩២.២១២ | -២% |
| ប្រាក់ចំណេញមុនដកពន្ធ | ១.០៩៣.៨៤៤ | ១.៥៨៤.៤៤៨ | ១.០៦០.៦៩៣ | ៣0% |
| ប្រាក់ចំណេញសុទ្ធក្រោយដកពន្ធ | ៨៧១.៦២០ | ១.២៦៨.០២២ | ៨៥៦.០៩៥ | -៣១% |
| ចំណេញក្នុងមួយភាគហ៊ុន | $0,0៧ | $៦,១៨ | $៤,១៧ | -៩៨% |
| ភាគលាភ ២ | $0,00 | $0,00 | $0,00 | 0% |

១ គិតពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤

២ ភាគលាភ មិនត្រូវបានបែងចែកពីប្រាក់ចំណេញសុទ្ធក្រោយដកពន្ធ (ធនាគារ អេស៊ីលីដា ភីអិលស៊ី, ក្រុមហ៊ុនមេ, កាន់កាប់ភាគហ៊ុនអេស៊ីលីដា ត្រេននីង សេនធ័រ១00%)



វគ្គសិក្ខាសាលាផ្លាស់ប្តូរបទពិសោធន៍លើការគ្រប់គ្រងវិស័យមីក្រូហិរញ្ញវត្ថុ រវាងធនាគារជាតិ នៃកម្ពុជា និងក្រសួងហិរញ្ញវត្ថុ នៃប្រទេសមីយ៉ាន់ម៉ា ដែលរៀបចំដោយ អេស៊ីលីដា ត្រេននីង សេនធ័រ នៅប្រទេសមីយ៉ាន់ម៉ា



វគ្គសិក្ខាសាលាផ្លាស់ប្តូរបទពិសោធន៍ រវាងធនាគារជាតិ នៃកម្ពុជា និងធនាគារជាតិឡាវ ដែលរៀបចំដោយ អេស៊ីលីដា ត្រេននីង សេនធ័រ នៅព្រះរាជាណាចក្រកម្ពុជា

# ចំណុចសំខាន់ៗក្នុងឆ្នាំ២០១៤

- ទ្រព្យសកម្មកើនឡើង ៤៤១% រហូតដល់ ១៦.៥២០.៣១៦ ដុល្លារអាមេរិក
- ប្រាក់ចំណេញសុទ្ធក្រោយដកពន្ធថយចុះ ៣១% មកនៅត្រឹម ៨៧១.៦២០ ដុល្លារអាមេរិក
- មូលនិធិម្ចាស់ហ៊ុនកើនឡើង ៥៨៣% រហូតដល់ ១៥.៧៧៩.៣៨៦ ដុល្លារអាមេរិក
- អនុបាតចំណាយប្រតិបត្តិការកើនឡើងពី ៣២,២១% រហូតដល់ ៣៩,០២%
- អត្រាប្រាក់ចំណូលក្រៅពីការហ៊ិរញ្ញ (លើកលែងចំណូលពីប្រាក់ជំនួយ) ធៀបនឹងចំណូលដុល កើនឡើងពី ១៤,០០% ដល់ ១៤,៨១%
- បានបណ្តុះបណ្តាលកម្មករនិយោជិតធនាគារ អេស៊ីលីដា ភីអិលស៊ី ចំនួន ១៨៥វគ្គ មានសិក្ខាកាមចូលរួមសរុបចំនួន ៦.៦៦៦នាក់
- បានបណ្តុះបណ្តាលកម្មករនិយោជិតក្រុមហ៊ុនបុត្រសម្ព័ន្ធក្រៅប្រទេសចំនួន ៩វគ្គ មានសិក្ខាកាមចូលរួមសរុបចំនួន ១៩៩ នាក់
- បានបណ្តុះបណ្តាល និងចែករំលែកបទពិសោធន៍សម្រាប់ស្ថាប័នខាងក្រៅចំនួន ៣៧វគ្គ មានសិក្ខាកាមចូលរួមសរុបចំនួន ៥២៨នាក់
- បានបើកវគ្គបណ្តុះបណ្តាលអភិវឌ្ឍន៍ជំនាញសម្រាប់និស្សិតចំនួន ២៨ វគ្គ មានសិក្ខាកាមចូលរួមសរុប ៦៤៩ នាក់
- ចាត់ចែងបណ្តុះកម្មសិក្សាដល់និស្សិត មានចំនួន ៣៤៨ នាក់
- បានបើកវគ្គបណ្តុះបណ្តាលថ្នាក់ភាសាអង់គ្លេសទូទៅ (ត្រីមាសទីមួយ) សម្រាប់កម្មករនិយោជិត ធនាគារ អេស៊ីលីដា ភីអិលស៊ី និងសាធារណៈជនទូទៅ ចំនួន ៤ ថ្នាក់ មានសិក្ខាកាមចូលរួមសរុប ៧០ នាក់ ។



គណៈប្រតិភូសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ( IFC ) ជួបពិភាក្សាការងារជាមួយ ថ្នាក់ដឹកនាំ អេស៊ីលីដា ត្រេននីង សេនធ័រ ស្តីពីគម្រោងវិនិយោគបង្កើតវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា




ប្រធានក្រុមប្រឹក្សាភិបាល និងអគ្គនាយក អេស៊ីលីដា ត្រេននីង សេនធ័រ ធ្វើទស្សនកិច្ចនៅសកលវិទ្យាល័យមួយចំនួន នៅកោះតៃវ៉ាន់

# លទ្ធផលដែលបានអនុវត្ត

## ទ្រព្យសកម្មសរុប/មូលនិធិម្ចាស់ហ៊ុន និងផលលើមូលធន

- មូលនិធិម្ចាស់ហ៊ុន (គិតជាដុល្លារអាមេរិក)
- ទ្រព្យសកម្មសរុប (គិតជាដុល្លារអាមេរិក)
- ផលលើមូលធន




## ចំនួនសិក្ខាកាម

- ការបណ្តុះបណ្តាលកម្មករនិយោជិតក្រុមហ៊ុនបុត្រសម្ព័ន្ធក្រៅប្រទេស
- ការបណ្តុះបណ្តាល និងចែករំលែកបទពិសោធន៍ សម្រាប់ស្ថាប័នខាងក្រៅ
- វគ្គបណ្តុះបណ្តាលជំនាញសម្រាប់និស្សិត
- ចាត់ចែងបណ្តុះកម្មសិក្សាដល់និស្សិត
- ថ្នាក់ភាសាអង់គ្លេសទូទៅ
- ការបណ្តុះបណ្តាលកម្មករនិយោជិត ធនាគារ អេស៊ីលីដា ភីអិលស៊ី



# មាតិកា


របាយការណ៍ប្រធានក្រុមប្រឹក្សាភិបាល . . . ៨
របាយការណ៍អគ្គនាយក . . . ១១
អង្គការលេខ . . . ១៤
ភាគទុនិក . . . ១៥
ក្រុមប្រឹក្សាភិបាល . . . ១៦
គណៈកម្មាធិការប្រតិបត្តិ . . . ១៨
ទីប្រឹក្សា . . . ២១
ក្រមសីលធម៌ . . . ២២
របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សវនករឯករាជ . . . ២៣
ស្ថាប័នដែលទទួលសេវាហ្វឹកហ្វឺន . . . ៤៣
ការិយាល័យកណ្តាល ធនាគារ អេស៊ីលីដា និងបុត្រសម្ព័ន្ធ . . . ៥០
សកម្មភាពបណ្តុះបណ្តាល . . . ៥១




គណៈប្រតិភូពី Asian Institute of Technology ( AIT ) ពិភាក្សាអំពីកិច្ចសហប្រតិបត្តិការសិក្សាជាមួយ អេស៊ីលីដា ត្រេននីង សេនធ័រ



គណៈប្រតិភូ Elite Study In Taiwan ( ESIT ) ធ្វើទស្សនកិច្ច និងពិភាក្សាអំពីកិច្ចសហប្រតិបត្តិការសិក្សា ជាមួយ អេស៊ីលីដា ត្រេននីង សេនធ័រ

# របាយការណ៍ប្រធានក្រុមប្រឹក្សាភិបាល



**បណ្ឌិត សូ ផននរាវី**

ប្រធានក្រុមប្រឹក្សាភិបាល

ការបន្តយកចិត្តទុកដាក់ឥតឈប់ឈរ ក្នុងវិស័យអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈការងារ ដល់កម្មករនិយោជិតគ្រប់ជាន់ថ្នាក់ គឺជាយុទ្ធសាស្ត្រដ៏សំខាន់ដែលធ្វើឱ្យក្រុមហ៊ុន ស្ថាប័នរីកចម្រើន និងមាននិរន្តរភាព។ មិនតែប៉ុណ្ណោះ ការអប់រំ និង បណ្តុះបណ្តាលវិជ្ជាជីវៈ គឺជាយុទ្ធសាស្ត្រដ៏សំខាន់ក្នុងចំណោមយុទ្ធសាស្ត្រទាំងឡាយ ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម ឱ្យរីកចម្រើន ។ ដូច្នេះហើយ ការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងវិស័យធនាគារ-ហិរញ្ញវត្ថុ ដ៏មានគុណភាព គឺជាទិសដៅចម្បងនិងចាំបាច់បំផុតរបស់ អេស៊ីលីដា ត្រេននីង សេនធ័រ ដើម្បីរួមចំណែកអភិវឌ្ឍន៍ធនធានមនុស្ស នៅក្នុងវិស័យអប់រំ និងបណ្តុះបណ្តាលជំនាញ ឆ្លើយតបទៅនឹងតម្រូវការធនធានមនុស្សប្រកបដោយគុណភាពខ្ពស់ នៅក្នុងទីផ្សារការងារ ។ ម្យ៉ាងវិញទៀត គឺដើម្បីផ្សារភ្ជាប់នូវជំនឿទុកចិត្តរបស់សិក្ខាកាមទាំងនៅក្នុង និងក្រៅប្រទេស ជាមួយនឹងគម្រោងការកម្លាយខ្លួនទៅជាវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ឈានមុខគេនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

## វិស័យអប់រំកម្ពុជាក្នុងឆ្នាំ២០១៤

លទ្ធផលដែលសម្រេចបានក្នុងឆ្នាំ២០១៣ ដល់២០១៤ របស់ក្រសួងអប់រំ យុវជន និងកីឡា បានឆ្លុះបញ្ចាំងពីការរីកចម្រើនថ្មីៗថែមទៀត ទាំងបរិមាណ និងគុណភាព ក្នុងវិស័យអប់រំ យុវជន និងកីឡា នៅក្នុងប្រទេសកម្ពុជា ក្នុងដំណាក់កាលថ្មីនៃការធ្វើសមាហរណកម្មក្នុងតំបន់ និងសកលលោក។ ក្នុងឆ្នាំសិក្សា ២០១៣-២០១៤ កំណែទម្រង់ឧត្តមសិក្សាសំខាន់ៗរួមមាន៖ ការរៀបចំចក្ខុវិស័យឧត្តមសិក្សាឆ្នាំ២០៣០ ការផ្ទេរសិទ្ធិឱ្យគ្រឹះស្ថានឧត្តមសិក្សាទទួលខុសត្រូវ ការចេញសញ្ញាបត្រ ការរៀបចំផែនការយុទ្ធសាស្ត្រនៅតាមគ្រឹះស្ថានឧត្តមសិក្សា និងសកម្មភាពស្រាវជ្រាវ។

គិតមកដល់បច្ចុប្បន្ននេះ នៅទូទាំងប្រទេសកម្ពុជា មានគ្រឹះស្ថានឧត្តមសិក្សាចំនួន១១០ គឺកើនឡើងចំនួន៥ បើប្រៀបធៀបជាមួយឆ្នាំ២០១៣ នៅក្នុងនោះគ្រឹះស្ថានឧត្តមសិក្សារដ្ឋមានចំនួន៤៣ និងឯកជនមានចំនួន៦៧ ដែលមានទីតាំងនៅ ១៩ខេត្ត និងរាជធានីភ្នំពេញ។ គ្រឹះស្ថានឧត្តមសិក្សា ៦៣ (រដ្ឋ៩ និងឯកជន៥៤) ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា និងគ្រឹះស្ថានឧត្តមសិក្សា៤៧ទៀត ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងស្ថាប័ន១៣ ផ្សេងទៀត។

និស្សិតកំពុងសិក្សានៅគ្រឹះស្ថានឧត្តមសិក្សា ចាប់ពីថ្នាក់បរិញ្ញាបត្ររង ដល់ថ្នាក់បណ្ឌិតមានចំនួនសរុប ២៤៩.០៩២ នាក់ (ស្រី៤១,៦%) ដែលក្នុងនោះ ថ្នាក់បរិញ្ញាបត្ររងមាននិស្សិតកំពុងសិក្សាចំនួន ១៥.៦៣៥ នាក់ (ស្រី៤៦,៧%) ថ្នាក់បរិញ្ញាបត្រមាននិស្សិតកំពុងសិក្សាចំនួន ២១៤.២៦៦នាក់ (ស្រី៤៣,២%) ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ មាននិស្សិតកំពុងសិក្សាចំនួន ១៨.០១០នាក់ (ស្រី២០,៩%) និងថ្នាក់បណ្ឌិតមាននិស្សិតកំពុងសិក្សាចំនួន១.១៨១នាក់(ស្រី៥,០%) ។



កិច្ចប្រជុំក្រុមប្រឹក្សាភិបាល អេស៊ីលីដា ត្រេននីង សេនធ័រ

# ការចូលរួមចំណែកយ៉ាងសកម្មរបស់ អេស៊ីលីដា ត្រេននីង សេនធ័រ នៅក្នុងវិស័យអប់រំ និងបណ្តុះបណ្តាលជំនាញធនាគារ និងហិរញ្ញវត្ថុ

អេស៊ីលីដា ត្រេននីង សេនធ័រ បាននិងកំពុងបន្តសកម្មភាពផ្តល់ការបណ្តុះបណ្តាល ដើម្បីឆ្លើយតបទៅនឹងតម្រូវការ របស់ក្រុមហ៊ុនមេ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ ទាំងក្នុង និងក្រៅប្រទេស ក្នុងការអភិវឌ្ឍធនធានមនុស្សឱ្យមានសមត្ថភាពខ្ពស់ ដើម្បីបន្តផ្តល់នូវសេវាកម្មបទដ្ឋានកម្រិតខ្ពស់បំផុតជូនដល់អតិថិជនរបស់ខ្លួន ។

ដើម្បីគាំទ្រដល់ការរីកចម្រើនយ៉ាងឆាប់រហ័សរបស់ក្រុមហ៊ុនមេ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ ទាំងក្នុងនិងក្រៅប្រទេស និងបន្តរក្សាបាននូវឧត្តមភាពក្នុងការប្រកួតប្រជែងនៅលើទីផ្សារ ការបណ្តុះបណ្តាល និងអភិវឌ្ឍន៍សមត្ថភាពវិជ្ជាជីវៈ ដល់កម្មករនិយោជិតឱ្យមានសមត្ថភាពខ្ពស់ បានក្លាយទៅជាយុទ្ធសាស្ត្រអាទិភាពចម្បងមួយ ក្នុងចំណោមយុទ្ធសាស្ត្រអាទិភាពចម្បងសំខាន់ៗរបស់ ធនាគារ អេស៊ីលីដា ដែលបច្ចុប្បន្នគឺជាធនាគារលំដាប់លេខ១ នៅក្នុងប្រទេសកម្ពុជា និងកំពុងរក្សាបាននូវភាពនាំមុខក្នុងបេសកកម្ម បណ្តល់សេវាកម្មធនាគារ និងហិរញ្ញវត្ថុប្រកបដោយគុណភាពកម្រិតខ្ពស់បំផុត។ ជាមធ្យមនៅក្នុងឆ្នាំ ២០១៤ បុគ្គលិកធនាគារ អេស៊ីលីដា ម្នាក់ៗ ទទួលបានការបណ្តុះបណ្តាលចំនួន ៤ដង ។

ផ្តើមចេញពីការបណ្តុះបណ្តាល និងអភិវឌ្ឍន៍សមត្ថភាពវិជ្ជាជីវៈដ៏មានគុណភាព ធនាគារ អេស៊ីលីដា បានក្លាយទៅជាប្រភពផ្គត់ផ្គង់ធនធានមនុស្ស ដែលប្រកបដោយចំណេះ ជំនាញ និងសីលធម៌ សម្រាប់វិស័យហិរញ្ញវត្ថុ និងធនាគារ។ និយោជិតរបស់ ធនាគារ អេស៊ីលីដា បានក្លាយជាគោលដៅរបស់បណ្តាធនាគារ ស្ថាប័នមីក្រូហិរញ្ញវត្ថុ និងអង្គការប្រតិបត្តិការឥណទានជាច្រើនផ្សេងទៀត ក្នុងការជ្រើសរើស ឬទាក់ទាញធ្វើជាអ្នកជំនាញឯកទេស ឬ ថ្នាក់ដឹកនាំជាន់ខ្ពស់របស់ខ្លួន។

លើសពីនេះ ដើម្បីចូលរួមចំណែក នៅក្នុងការកសាងសមត្ថភាពធនធានមនុស្សនៅក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ អេស៊ីលីដា ត្រេននីង សេនធ័រ បានចូលរួមជាចលករដ៏សកម្ម ក្នុងបេសកកម្មចែករំលែកនូវចំណេះ ជំនាញ និងបទពិសោធន៍ជោគជ័យ របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ក៏ដូចជាជោគជ័យក្នុងវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ របស់ប្រទេសកម្ពុជាជូនដល់ប្រតិបត្តិករ និងនិយតករផ្សេងទៀត ពីបណ្តាប្រទេសក្នុងតំបន់អាស៊ាន និងអន្តរជាតិ ស្របទៅតាមទស្សនវិស័យដ៏ទូលំទូលាយ និងជាវប្បធម៌ចែករំលែកដ៏ថ្លៃថ្លា របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី និងរាជរដ្ឋាភិបាលកម្ពុជា ក្រោមកិច្ចសហការផ្តល់មូលនិធិជំនួយសប្បុរសរបស់រដ្ឋាភិបាលអាល្លឺម៉ង់ តាមរយៈធនាគារ អភិវឌ្ឍន៍ អាល្លឺម៉ង់ (KfW) ។

ការហ្វឹកហ្វឺន និងការអភិវឌ្ឍ គឺស្ថិតនៅក្នុងបេះដូងជាប់ជានិច្ចរបស់ក្រុមប្រឹក្សាភិបាល ថ្នាក់ដឹកនាំ និងកម្មករនិយោជិតគ្រប់លំដាប់ថ្នាក់ នៃអេស៊ីលីដា ត្រេននីង សេនធ័រ ក្នុងការបង្កើនសមត្ថភាពវិជ្ជាជីវៈ ប្រកបដោយសីលធម៌ ជូនដល់សិក្ខាកាម ទាំងក្នុង និងក្រៅប្រទេស ដើម្បីធានាបាននូវការផ្តល់សេវាកម្ម តាមបទដ្ឋានអន្តរជាតិ។

## លទ្ធផលទទួលបានក្នុងឆ្នាំ២០១៤

ដើម្បីឆ្លើយតបទៅនឹងទស្សនៈ និងបេសកកម្ម ក្នុងការចូលរួមអភិវឌ្ឍន៍ធនធានមនុស្សរបស់ខ្លួន ក្នុងឆ្នាំ២០១៤ អេស៊ីលីដា ត្រេននីង សេនធ័រ បានផ្តល់ការបណ្តុះបណ្តាលដល់កម្មករនិយោជិត ធនាគារ អេស៊ីលីដា ភីអិលស៊ី បានចំនួន ៤៥,១៣៣ នាក់ ក្នុងនោះកម្មករនិយោជិតថ្មីដែលជានិស្សិតទើបតែបញ្ចប់ការសិក្សាពីថ្នាក់ឧត្តមសិក្សា ចំនួន ១,៥៥៥នាក់។ ក្រៅពីនេះ អេស៊ីលីដា ត្រេននីង សេនធ័រ បានផ្តល់ការបណ្តុះបណ្តាលដល់កម្មករនិយោជិតក្រុមហ៊ុនបុត្រសម្ព័ន្ធក្រៅប្រទេស របស់ ធនាគារ អេស៊ីលីដា ភីអិលស៊ី ចំនួន ១៩៩នាក់ និងបានផ្តល់ការបណ្តុះបណ្តាល និងចែករំលែកបទពិសោធន៍ ជូនស្ថាប័នខាងក្រៅ ចំនួន ៥២៨នាក់ ក្នុងនោះ មានសិក្ខាកាមក្នុងស្រុកមកពីស្ថាប័នចំនួន ៦៤ និងសិក្ខាកាមអន្តរជាតិចំនួន ១៩ស្ថាប័ន មកពីប្រទេសចំនួន៦ (ប៊ូតាន ចិន ឡាវ ភូមា ស្រីលង្កា និងវៀតណាម) ។

ដើម្បីឱ្យនិស្សិតទទួលបាននូវគុណវុឌ្ឍិខ្ពស់ សម្រាប់ឱកាសជោគជ័យក្នុងការស្វែងរកការងារជាមួយស្ថាប័នហិរញ្ញវត្ថុនានា និងការធ្វើជំនួញផ្ទាល់ខ្លួន ក្នុងឆ្នាំ២០១៤ អេស៊ីលីដា ត្រេននីង សេនធ័រ បានបើកវគ្គបណ្តុះបណ្តាលជំនាញសម្រាប់និស្សិតចំនួន ២៨វគ្គ ដែលមានសិក្ខាកាមចូលរួមសរុបចំនួន ៦៤៩នាក់។

ជាមួយគ្នានេះដែរ ដើម្បីចូលរួមក្នុងការអភិវឌ្ឍធនធានមនុស្សនៅក្នុងសង្គម អេស៊ីលីដា ត្រេននីង សេនធ័រ បានផ្តល់ឱកាសដល់និស្សិតជាតិ



ប្រធានក្រុមប្រឹក្សាភិបាល អេស៊ីលីដា ត្រេននីង សេនធ័រ ថតរូបជាមួយសាស្ត្រាចារ្យ និងសិក្ខាកាមវគ្គទស្សនកិច្ចសិក្សាលើការគ្រប់គ្រងឥណទាន

និងអន្តរជាតិ ដែលកំពុងសិក្សានៅតាមគ្រឹះស្ថានឧត្តមសិក្សា មកធ្វើកម្មសិក្សាដោយឥតគិតកម្រៃនៅ ធនាគារ អេស៊ីលីដា ភីអិលស៊ី សម្រាប់ការសិក្សាស្រាវជ្រាវលើ ចំណេះដឹង ជំនាញ ដើម្បីសរសេររបាយការណ៍ ឬសារណាបញ្ចប់ការសិក្សារបស់ពួកគេ។ លទ្ធផលបូកបន្តគិតមកដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ មាននិស្សិតជាតិសរុបចំនួន ១១,៦៤៦នាក់ មកពីគ្រឹះស្ថានឧត្តមសិក្សាចំនួន ៦២ និងនិស្សិតអន្តរជាតិចំនួន ៥៣នាក់ មកពីគ្រឹះស្ថានឧត្តមសិក្សាចំនួន ២៦ នៃ ១៤ប្រទេស (អូស្ត្រាលី ប៊ែលហ្សិក ចិន អង់គ្លេស បារាំង អាល្លឺម៉ង់ ឥណ្ឌា ជប៉ុន ឡាវ ម៉ាឡេស៊ី រុស្ស៊ី សិង្ហបុរី ថៃ និងអាមេរិក) បានទទួលអត្ថប្រយោជន៍ពីកម្មវិធីបណ្ដុះ កម្មសិក្សារបស់ អេស៊ីលីដា ត្រេននីង សេនធ័រ។

សម្រាប់លទ្ធផលហិរញ្ញវត្ថុឆ្នាំ២០១៤ អេស៊ីលីដា ត្រេននីង សេនធ័រ បានទទួលប្រាក់ចំណេញសុទ្ធក្រោយបង់ពន្ធ ចំនួន ៨៧១.៦២០ ដុល្លារអាមេរិក ខណៈទ្រព្យសកម្មបានកើនឡើង ៤៤២% ហូតដល់ ១៦.៥២០.៣១៦ ដុល្លារអាមេរិក តាមរយៈការបន្ថែមទុនវិនិយោគលើការទិញដី សម្រាប់សាងសង់អាគារ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ដែលការវិនិយោគបន្ថែមនេះ ធ្វើឱ្យមូលនិធិម្ចាស់ហ៊ុន បានកើនឡើងរហូតដល់ចំនួន ១៥.៧៧៩.៣៨៦ ដុល្លារអាមេរិក។ អនុបាតប្រសិទ្ធភាពប្រតិបត្តិការបានកើនឡើងពី ៣២,១៥% រហូតដល់ ៤០,២០% និងអត្រាប្រាក់ចំណូល ដែលបានមកពីការហ្វឹកហ្វឺន និងបណ្ដុះបណ្ដាលសិក្ខាកាមមកពីខាងក្រៅ (ទាំងក្នុង និងក្រៅប្រទេស) រួមនឹងចំណូលផ្សេងៗ ធៀបនឹងចំណូលដុល បានធ្លាក់ចុះពី១៣,៩៤% មកត្រឹម ១០,៨៦%។

## ទស្សនវិស័យ និងផែនការយុទ្ធសាស្ត្រឆ្នាំ២០១៥

ដើម្បីសម្រេចបានសមិទ្ធផលសម្រាប់ឆ្នាំ២០១៤ អេស៊ីលីដា ត្រេននីង សេនធ័រ បានកំណត់ផែនការជាអាទិភាពដូចតទៅ ៖

១- បន្តពង្រឹងលើការប្រតិបត្តិគោលការណ៍ទាំងអស់ឱ្យបានខ្ជាប់ខ្ជួន និងជំរុញការអភិវឌ្ឍគោលការណ៍ប្រតិបត្តិ និងគ្រប់គ្រងកិច្ចការជំនួញ ឱ្យមានភាពត្រឹមត្រូវគ្រប់គ្រាន់ និងទាន់សម័យ ស្របតាមការវិវត្តថ្មីៗរបស់ក្រុមហ៊ុនមេ និងទីផ្សារ ដោយធានាបាននូវអនុលោមភាពតាមច្បាប់ជាតិ និងអន្តរជាតិ។

២- ធ្វើឱ្យមានភាពចម្រុះនៃប្រភពចំណូល ដោយកាត់បន្ថយបន្តិចម្ដងៗ លើការពឹងផ្អែកប្រភពចំណូលពីក្រុមហ៊ុនមេតាមរយៈការបង្កើតសេវាកម្មអប់រំបណ្ដុះបណ្ដាលថ្មីៗបន្ថែម ដែលមានទីផ្សារគោលដៅធំទូលាយ ដូចជាការបង្កើតវគ្គខ្លីៗសម្រាប់និស្សិត បង្កើតថ្នាក់កម្រិតឧត្តមសិក្សា សេវាប្រឹក្សាយោបល់ សេវាកម្មស្រាវជ្រាវលើវិស័យហិរញ្ញវត្ថុ និងធនាគារ សេវាកម្មសិក្សាទីផ្សារសេវាហិរញ្ញវត្ថុ និងសហគ្រាសខ្នាតមធ្យម ។ល។ ដោយមានការសហការ ជាមួយក្រុមហ៊ុនមេ និងដៃគូផ្សេងទៀត។

៣- វិនិយោគទៅលើការទិញដី សម្រាប់សាងសង់អាគារសិក្សាលំដាប់ស្ដង់ដារខ្ពស់បំផុត ដោយមានបំពាក់នូវគ្រឿងឧបករណ៍ សម្ភារបរិក្ខារ និងឧបទ្ទេសពេញលេញ ទំនើបៗ ដែលនឹងបង្កើតបរិយាកាសល្អ អំណោយផលដល់ការសិក្សារៀនសូត្ររបស់សិក្ខាកាម និងនិស្សិត និងដើម្បីជាការរួមចំណែកដល់ការសាងកេរ្តិ៍ឈ្មោះ ជាគ្រឹះស្ថានសិក្សាដែលមានកម្រិតបទដ្ឋានខ្នាតអន្តរជាតិ ។

៤- អភិវឌ្ឍ អេស៊ីលីដា ត្រេននីង សេនធ័រ ឱ្យក្លាយទៅជាគ្រឹះស្ថានសិក្សាខ្នាតអន្តរជាតិ ដែលមានការទទួលស្គាល់ជាសកល ក្នុងការផ្ដល់ជូននូវសេវាកម្មអប់រំ បណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈ លើវិស័យធនាគារ និងហិរញ្ញវត្ថុ ប្រកបដោយគុណភាព និងសីលធម៌កម្រិតខ្ពស់បំផុត ជូនដល់បុគ្គលិកអេស៊ីលីដា សិក្ខាកាមពីស្ថាប័នទាំងឡាយនៅក្នុង និងក្រៅប្រទេស និងនិស្សិតពីបណ្ដាប្រទេសក្នុងតំបន់អាស៊ាន ដែលធនាគារ អេស៊ីលីដា កំពុងពង្រីកបណ្ដាញប្រតិបត្តិការទៅកាន់ទីនោះ ។

៥- ផ្ដោតការយកចិត្តទុកដាក់ខ្ពស់ក្នុងការវិនិយោគ លើធនធានមនុស្សតាមរយៈ ការកសាងសមត្ថភាពបន្ថែមដល់ថ្នាក់គ្រប់គ្រង សាស្ត្រាចារ្យ និងបុគ្គលិកជំនាញដែលពាក់ព័ន្ធ ទាំងចំណេះដឹង ជំនាញ និងចំណេះដឹងភាសាយាន ដើម្បីឱ្យធនធានមនុស្សរបស់ អេស៊ីលីដា ត្រេននីង សេនធ័រ បំពេញការងារប្រកបដោយ ភាពវិជ្ជាជីវៈ គុណភាព ប្រសិទ្ធភាព និងផលិតភាព ការងារខ្ពស់ធានាបាននូវបណ្ដុះសេវាកម្មអប់រំបណ្ដុះបណ្ដាលវិជ្ជាជីវៈ ប្រកបដោយគុណភាពខ្ពស់បំផុត។

៦- អភិវឌ្ឍ អេស៊ីលីដា ត្រេននីង សេនធ័រ ឱ្យក្លាយទៅជាមជ្ឈមណ្ឌលសិក្សាស្រាវជ្រាវ និងអភិវឌ្ឍព័ត៌មានដ៏ទូលំទូលាយមួយ លើវិស័យហិរញ្ញវត្ថុ សហគ្រាសខ្នាតតូច និងមធ្យម និងសិក្សាអប់រំ ដើម្បីផ្ដល់ការប្រឹក្សាយោបល់ដល់ស្ថាប័នអន្តរជាតិនានាដែលចង់ស្វែងយល់ និងមានបំណងចូលមកវិនិយោគទុន នៅក្នុងប្រទេសកម្ពុជា លើវិស័យទាំងនេះ។

ខ្ញុំសូមសម្ដែងនូវគារវកិច្ច និងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះធនាគារ អេស៊ីលីដា ភីអិលស៊ី ដែលជាក្រុមហ៊ុនមេ អតិថិជន និងសាធារណជន ព្រមទាំងដៃគូជាតិ អន្តរជាតិ ជាពិសេសរាជរដ្ឋាភិបាលកម្ពុជា ដែលបានផ្ដល់ការជឿទុកចិត្ត និងគាំទ្រដល់ អេស៊ីលីដា ត្រេននីង សេនធ័រ ក្នុងបេសកកម្ម អប់រំ បណ្ដុះបណ្ដាលធនធានមនុស្សកន្លងមក។ ម៉្យាងវិញទៀត ខ្ញុំក៏សូមសម្ដែងនូវអំណរគុណ និងកោតសរសើរចំពោះសមាជិក-សមាជិកាក្រុមប្រឹក្សាភិបាល ក៏ដូចជា ថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់ នៃអេស៊ីលីដា ត្រេននីង សេនធ័រ ដែលមានការប្ដេជ្ញាចិត្តខ្ពស់ និងទទួលជោគជ័យក្នុងការបំពេញកិច្ចការងារមួយឆ្នាំកន្លងមកនេះ ។

ទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធពរជូនចំពោះលោកអ្នក ព្រមទាំងក្រុមគ្រួសារទាំងអស់ ទទួលបាននូវសុខភាពល្អ សិរីសួស្ដី ជោគជ័យមង្គល និងវិបុលសុខជានិច្ចនិរន្តរ៍តរៀងទៅ។

បណ្ឌិត សូ ផនណារី

*ប្រធានក្រុមប្រឹក្សាភិបាល*

ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៥

# របាយការណ៍អគ្គនាយក



**លោក ឆន ពន្លឺ**

អគ្គនាយក

លទ្ធផលនៃប្រតិបត្តិការប្រចាំឆ្នាំ២០១៤ ឆ្លុះបញ្ចាំងអំពីជំហានដ៏ល្អប្រសើរ ក្នុងបេសកកម្មអប់រំ បណ្តុះបណ្តាលរបស់ អេស៊ីលីដា ត្រេននីង សេនធ័រ តាមរយៈការធ្វើកំណែទម្រង់រចនាសម្ព័ន្ធគ្រប់គ្រង ការរៀបចំធនធានមនុស្ស មូលដ្ឋានសម្ភាររូបវន្ត និងឧបទេស កម្មវិធីសិក្សា បច្ចេកទេស និងការអភិវឌ្ឍបន្ថែមនូវគោលការណ៍-នីតិវិធីចាំបាច់នានា ដើម្បីលើកស្ទួយគុណភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាលឱ្យកាន់តែល្អប្រសើរឡើង ឆ្លើយតបទៅនឹងតម្រូវការ និងការវិវឌ្ឍន៍ថ្មីៗរបស់ទីផ្សារ និងដើម្បីត្រៀមរៀបចំខ្លួនឱ្យបានល្អគ្រប់ជ្រុងជ្រោយ ក្នុងការអនុវត្តផែនការកម្លាយខ្លួនទៅជាគ្រឹះស្ថានឧត្តមសិក្សា ស្របតាមវិធានការ និងយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ របស់រាជរដ្ឋាភិបាលកម្ពុជា។ អេស៊ីលីដា ត្រេននីង សេនធ័រ ជានិច្ចកាល ប្តេជ្ញាប្រកាន់ខ្ជាប់នូវគោលការណ៍ សីលធម៌វិជ្ជាជីវៈ សង្គម ច្បាប់ និងបរិស្ថានកម្រិតខ្ពស់បំផុត បន្តរួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងកិច្ចអភិវឌ្ឍន៍ធនធានមនុស្ស ឱ្យមានសមត្ថភាពវិជ្ជាជីវៈខ្ពស់ ប្រកបដោយវិន័យ និងសីលធម៌ល្អប្រពៃ ដែលជាធាតុមួយដ៏សំខាន់ចាំបាច់បំផុត សម្រាប់ការអភិវឌ្ឍន៍ប្រទេសជាតិ។

## សមិទ្ធផលសម្រេចបានក្នុងឆ្នាំ២០១៤

### បរិយាកាសនៃការបណ្តុះបណ្តាល

- បានបណ្តុះបណ្តាលគ្រូហ្វឹកហ្វឺនថ្មីបន្ថែមទៀតចំនួន ១០២នាក់ (នៅលំដាប់ការិយាល័យកណ្តាល) និងចំនួន ៣២៥នាក់ (នៅលំដាប់សាខា) ដើម្បីលើកស្ទួយគុណភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាល ឆ្លើយតបទៅនឹងតម្រូវការ និងការវិវឌ្ឍន៍ថ្មីៗរបស់អតិថិជនខាងក្នុង និងខាងក្រៅ ។ លើសពីនេះ អេស៊ីលីដា ត្រេននីង សេនធ័រ បានរៀបចំវគ្គសិក្ខាសាលាបំពាក់បំប៉នគ្រូហ្វឹកហ្វឺនអេស៊ីលីដា ចំនួន ១២វគ្គ ដែលមានសិក្ខាកាមចូលរួមសរុបចំនួន ៥២៤នាក់ ។ ជាមធ្យមនៅក្នុងឆ្នាំ ២០១៤ បុគ្គលិកធនាគារ អេស៊ីលីដា ម្នាក់ៗ ទទួលបានការបណ្តុះបណ្តាល ចំនួន ៤ដង ។

- បានចាត់ចែងការបណ្តុះបណ្តាល ដល់កម្មករនិយោជិត ធនាគារ អេស៊ីលីដា ភីអិលស៊ី និងក្រុមហ៊ុនបុត្រសម្ព័ន្ធក្រៅប្រទេស ចំនួន ៤.៦០២ វគ្គ ដោយមានសិក្ខាកាមចូលរួមសរុបចំនួន ៤៦.១៥០នាក់ និងបានធ្វើការបណ្តុះបណ្តាល ចែករំលែកបទពិសោធន៍ ជោគជ័យរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី និងវិស័យមីក្រូហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា ជូនដល់និស្សិត និងសិក្ខាកាមមកពីស្ថាប័នខាងក្រៅ (ទាំងក្នុង និងក្រៅប្រទេស) សរុបចំនួន ៦៨ វគ្គ ដោយមានសិក្ខាកាមចូលរួមសរុបចំនួន ១.២៣៨ នាក់។

- បានចុះអនុស្សារណៈយោគយល់គ្នា ជាមួយគ្រឹះស្ថាន ធនាគារ មីក្រូ-ហិរញ្ញវត្ថុ អង្គការប្រតិបត្តិការឥណទាន និងក្រុមហ៊ុនឯកជនផ្សេងៗទៀត ចំនួន ៤២ ដើម្បីផ្តល់ឱកាសការងារដល់និស្សិតដែលបានបញ្ចប់ដោយជោគជ័យ ក្នុងវគ្គសិក្សាអភិវឌ្ឍជំនាញខ្លីៗ របស់អេស៊ីលីដា ត្រេននីង សេនធ័រ ។

- បានបន្តសហការយ៉ាងជិតស្និទ្ធ ជាមួយសមាគមមីក្រូហិរញ្ញវត្ថុប្រទេសចិន ក្នុងការរៀបចំវគ្គទស្សនកិច្ចសិក្សាមួយ ជូនដល់សមាជិកនៃសមាគមមីក្រូហិរញ្ញវត្ថុ និងសមាគមធនាគារ ប្រទេសចិន មកកាន់ ប្រទេសកម្ពុជា ដើម្បីទទួលបាននូវការចែករំលែកបទពិសោធន៍ជោគជ័យ របស់ ធនាគារ អេស៊ីលីដា និងវិស័យមីក្រូហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា ក្រោមការឧបត្ថម្ភពីមូលនិធិអាហារូបករណ៍របស់ធនាគារ អភិវឌ្ឍន៍ អាល្លឺម៉ង់ (KfW) ។

- បានបន្តសហការយ៉ាងជិតស្និទ្ធ ជាមួយធនាគារជាតិនៃកម្ពុជា ដើម្បីចែករំលែកបទពិសោធន៍ជោគជ័យ ក្នុងវិស័យមីក្រូហិរញ្ញវត្ថុ និងធនាគារ ជូនដល់និយតករក្នុងតំបន់ ។ ក្រោមការឧបត្ថម្ភពីមូលនិធិអាហារូបករណ៍របស់ធនាគារ អភិវឌ្ឍន៍ អាល្លឺម៉ង់ (KfW) ក្នុងឆ្នាំ២០១៤ អេស៊ីលីដា ត្រេននីង សេនធ័រ បានរៀបចំសម្របសម្រួលវគ្គចែករំលែកបទពិសោធន៍ ចំនួនពីរវគ្គ នៅក្នុងប្រទេសកម្ពុជា រវាងធនាគារជាតិនៃកម្ពុជា និងធនាគារជាតិឡាវ និងរវាងធនាគារជាតិនៃកម្ពុជា និងក្រសួងហិរញ្ញវត្ថុនៃប្រទេសមីយ៉ាន់ម៉ា លើប្រធានបទរួម ស្តីពី "ការគ្រប់គ្រង និងត្រួតពិនិត្យ វិស័យមីក្រូហិរញ្ញវត្ថុ" ។

- បានបន្តពង្រឹងយន្តការគ្រប់គ្រង ត្រួតពិនិត្យ និងសម្របសម្រួលថ្នាក់រៀន និងការរៀនសូត្ររបស់សិក្ខាកាម ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ឡើង ដើម្បីធានាបាននូវ បរិយាកាសរៀនសូត្រល្អប្រសើរ និងឧត្តមភាពនៃការសិក្សា ។

- បានបន្តធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាពនៃការផ្សព្វផ្សាយ តាមរយៈការធ្វើទំនើបកម្មលើឧបករណ៍ និងមធ្យោបាយផ្សព្វផ្សាយ ជាពិសេសវេបសាយ អេស៊ីលីដា ត្រេននីង សេនធ័រ ក្នុងទិសដៅជំរុញសកម្មភាពផ្សព្វផ្សាយព័ត៌មាន ទាំងការបណ្តុះបណ្តាល សម្រាប់បុគ្គលិកធនាគារ អេស៊ីលីដា និងការផ្សព្វផ្សាយសេវាកម្មហ្វឹកហ្វឺន សម្រាប់អតិថិជនខាងក្រៅ និងសាធារណជន ឱ្យបានកាន់តែទូលំទូលាយ ។

## ការត្រៀមរៀបចំកម្លាយខ្លួន

• បានកែសម្រួលសំណុំបែបបទដាក់ពាក្យស្នើសុំកម្លាយខ្លួនជាគ្រឹះស្ថានឧត្តមសិក្សា ទៅក្រសួងអប់រំយុវជន និងកីឡា ក្រោមនាមករណ៍ថ្មី "**វិទ្យាស្ថានពាណិជ្ជសាស្ត្រ អេស៊ីលីដា**" ក្នុងជំនាញឯកទេសហិរញ្ញវត្ថុ និងធនាគារ ដើម្បីឱ្យស្របទៅនឹងកេរ្តិ៍ឈ្មោះ ភាពរឹងមាំ និងជោគជ័យរបស់ ធនាគារ អេស៊ីលីដា ភីអិលស៊ី ដែលមាន ធនធានមនុស្ស ប្រកបដោយសមត្ថភាពខ្ពស់ (ចំណេះ ជំនាញ បទពិសោធន៍) និងសីលធម៌ល្អ ។

• បានបញ្ជូនថ្នាក់ដឹកនាំជាន់ខ្ពស់ ឱ្យចូលរួមសន្និសីទថ្នាក់អន្តរជាតិ ដែលរៀបចំឡើងដោយសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ, IFC's 6th International Private Education Conference, ស្តីអំពី "Rethinking Education, Shaping the Future" ដើម្បីស្វែងយល់អំពីនិន្នាការ និងវិវឌ្ឍនាការថ្មីៗ ក្នុងវិស័យអប់រំ បណ្តុះបណ្តាល នៅលើឆាកអន្តរជាតិ ។

• បានបញ្ជូនថ្នាក់ដឹកនាំឱ្យទៅធ្វើទស្សនកិច្ចសិក្សា នៅគ្រឹះស្ថានឧត្តមសិក្សាល្បីៗនៅកោះតៃវ៉ាន់ រួមមាន National Kaohsiung First University of Science and Technology, National Sun Yat-sen University, Chung Yuan Christian University, Chao Yang University of Technology, National Chiao Tung University... ក្រោមការឧបត្ថម្ភពីមូលនិធិអាហារូបករណ៍របស់ ធនាគារ អភិវឌ្ឍន៍ អាល្លឺម៉ង់ (KfW) និង Elite Study In Taiwan Program (ESIT) ដើម្បីសិក្សាស្វែងយល់អំពី ប្រព័ន្ធនៃការអប់រំបណ្តុះបណ្តាល បទពិសោធន៍នៃការគ្រប់គ្រង ការអភិវឌ្ឍកម្មវិធីសិក្សាលំដាប់ថ្នាក់អន្តរជាតិ និងសិក្សាអំពីលទ្ធភាពនៃកិច្ចសហប្រតិបត្តិការលើកម្មវិធីមួយចំនួន ដូចជា ការផ្លាស់ប្តូរនិស្សិត សាស្ត្រាចារ្យ កម្មវិធីសិក្សា ការសិក្សាស្រាវជ្រាវរួម... និងដើម្បីត្រៀមរៀបចំ អនុវត្តផែនការកម្លាយខ្លួន ទៅជាគ្រឹះស្ថានឧត្តមសិក្សា ។

• បានបន្តធ្វើកំណែទម្រង់រចនាសម្ព័ន្ធគ្រប់គ្រង ការរៀបចំធនធានមនុស្ស មូលដ្ឋានសម្ភាររូបវន្ត និងឧបទេស កម្មវិធីសិក្សា បច្ចេកទេស និងការអភិវឌ្ឍគោលការណ៍-នីតិវិធីចាំបាច់នានា ដើម្បីត្រៀមរៀបចំអនុវត្តផែនការកម្លាយខ្លួន ទៅជាគ្រឹះស្ថានឧត្តមសិក្សា ឱ្យប្រព្រឹត្តទៅដោយរលូន ។

• បានវិនិយោគលើការទិញដីទំហំ ៧៥.៧៥០ ម៉ែត្រក្រឡា ដែលមានទីតាំងស្ថិតក្នុងខណ្ឌសែនសុខ រាជធានីភ្នំពេញ សម្រាប់ការបង្កើតវិទ្យាស្ថានពាណិជ្ជសាស្ត្រ អេស៊ីលីដា ដោយចំណាយទឹកប្រាក់សរុបអស់ចំនួន ១២.២១២.៩៣៦ ដុល្លារអាមេរិក ។

## លទ្ធផលប្រតិបត្តិការក្នុងឆ្នាំ២០១៤

- ទ្រព្យសកម្មកើនឡើងពី ៣.០៤៩.៧៥៤ ដុល្លារអាមេរិក រហូតដល់ ១៦.៥២០.៣១៦ ដុល្លារអាមេរិក ។
- មូលនិធិម្ចាស់ហ៊ុនកើនឡើងពី ២.៣០៧.៧៦៦ ដុល្លារអាមេរិក រហូតដល់ ១៥.៧៧៩.៣៨៦ ដុល្លារអាមេរិក ។
- អនុបាតប្រសិទ្ធភាពប្រតិបត្តិការបានកើនឡើងពី ៣២,១៥% រហូតដល់ ៤០,២០% ។
- អត្រាប្រាក់ចំណូលដែលបានមកពីការហ្វឹកហ្វឺននិងបណ្តុះបណ្តាលសិក្ខាកាមមកពីខាងក្រៅ (ទាំងក្នុង និងក្រៅប្រទេស) រួមនឹងចំណូលផ្សេងៗ ធៀបនឹងចំណូលដុល បានធ្លាក់ចុះពី ១៣,៩៤% មកត្រឹម ១០,៨៦%។
- ទទួលបានប្រាក់ចំណេញសុទ្ធក្រោយបង់ពន្ធចំនួន ៨៧១.៦២០ ដុល្លារអាមេរិក ។
- ការបណ្តុះបណ្តាលកម្មករនិយោជិតធនាគារ អេស៊ីលីដា ភីអិលស៊ី សម្រាប់ឆ្នាំ ២០១៤ ៖

| | | | | |
|---|---|---|---|---|
| - វគ្គហ្វឹកហ្វឺនកម្មករនិយោជិតថ្មី | ចំនួន ៣៧ វគ្គ | សរុបសិក្ខាកាម | ចំនួន | ២.៣៦៨ នាក់ |
| - វគ្គហ្វឹកហ្វឺនការងារដំបូង | ចំនួន ១.៣២០ វគ្គ | សរុបសិក្ខាកាម | ចំនួន | ១.៨៥៦ នាក់ |
| - វគ្គបណ្តុះបណ្តាលកម្មករនិយោជិតដែលកំពុងបម្រើការងារ | ចំនួន ៣.២២១ វគ្គ | សរុបសិក្ខាកាម | ចំនួន | ៤០.៩០៩ នាក់ |
| - វគ្គបណ្តុះបណ្តាលជំនាញគ្រូហ្វឹកហ្វឺនថ្មី | ចំនួន ៨ វគ្គ | សរុបសិក្ខាកាម | ចំនួន | ៤២៧ នាក់ |
| - វគ្គសិក្ខាសាលាបំពាក់បំប៉នគ្រូហ្វឹកហ្វឺន | ចំនួន ១២ វគ្គ | សរុបសិក្ខាកាម | ចំនួន | ៥២៤ នាក់ |

- ការបណ្តុះបណ្តាលកម្មករនិយោជិតក្រុមហ៊ុនបុត្រសម្ព័ន្ធក្រៅប្រទេស ធនាគារ អេស៊ីលីដា ភីអិលស៊ី ៖

| | | | | |
|---|---|---|---|---|
| - វគ្គហ្វឹកហ្វឺននៅនឹងកន្លែងការងារ | ចំនួន ០៤ វគ្គ | សរុបសិក្ខាកាម | ចំនួន | ៦៦ នាក់ |
| - វគ្គហ្វឹកហ្វឺននៅក្នុងថ្នាក់ | ចំនួន ០៥ វគ្គ | សរុបសិក្ខាកាម | ចំនួន | ១៣៣ នាក់ |

- ការបណ្តុះបណ្តាល និងចែករំលែកបទពិសោធន៍ សម្រាប់ស្ថាប័នខាងក្រៅ ៖

| | | | | |
|---|---|---|---|---|
| - វគ្គសិក្ខាសាលាសម្រាប់ស្ថាប័នក្នុងស្រុក | ចំនួន ៣០ វគ្គ | សរុបសិក្ខាកាម | ចំនួន | ៤៦៣ នាក់ |
| - វគ្គសិក្ខាសាលាខ្នាតអន្តរជាតិ | ចំនួន ០២ វគ្គ | សរុបសិក្ខាកាម | ចំនួន | ១៧ នាក់ |
| - វគ្គទស្សនកិច្ចសិក្សាសម្រាប់ស្ថាប័នពីក្រៅប្រទេស | ចំនួន ០៤ វគ្គ | សរុបអ្នកចូលរួម | ចំនួន | ៣៩ នាក់ |
| - វគ្គទស្សនកិច្ចសិក្សាសម្រាប់ស្ថាប័នក្នុងប្រទេស | ចំនួន ០១ វគ្គ | សរុបអ្នកចូលរួម | ចំនួន | ៩ នាក់ |

- វគ្គបណ្តុះបណ្តាលជំនាញសម្រាប់និស្សិត ចំនួន ២៨ វគ្គ សរុបសិក្ខាកាម ចំនួន ៦៤៩ នាក់ ។
- វគ្គបណ្តុះបណ្តាលភាសាអង់គ្លេសទូទៅ ចំនួន ០៤ ថ្នាក់ សរុបសិក្ខាកាម ចំនួន ៧០ នាក់ ។

## យុទ្ធសាស្ត្រអាទិភាពសម្រាប់ឆ្នាំ២០១៥ និងឆ្នាំបន្តបន្ទាប់

១- រៀបចំខ្លួនឱ្យក្លាយជាគ្រឹះស្ថានអប់រំ បណ្តុះបណ្តាល ដែលមានភាពលេចធ្លោ ជាមួយនឹងការប្រកាន់នូវគោលការណ៍ សីលធម៌វិជ្ជាជីវៈ វិធាននិន័យម៉ឺងម៉ាត់ គុណភាព តម្លាភាព និងគោរពតាមស្តង់ដារកម្រិតខ្ពស់នៃការសិក្សា និង ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ដើម្បីសម្រេចបាននូវទស្សនៈវិស័យជាគ្រឹះស្ថាននាំមុខក្នុងការផ្តល់សេវាកម្មអប់រំ បណ្តុះបណ្តាល ប្រកបដោយ គុណភាពខ្ពស់បំផុត ។

២- ផ្តោតទៅលើការវិនិយោគលើធនធានមនុស្ស តាមរយៈការកសាងសមត្ថភាពបន្ថែមដល់ថ្នាក់គ្រប់គ្រង សាស្ត្រាចារ្យ និងបុគ្គលិកជំនាញដែលពាក់ព័ន្ធទាំងចំណេះដឹង ជំនាញ និងចំណេះដឹងភាសាយាន ដើម្បីឱ្យធនធានមនុស្សរបស់ អេស៊ីលីដា ត្រៀមនឹង សេនផ៉ រ បំពេញការងារប្រកបដោយភាពជំនាញវិជ្ជាជីវៈ

គុណភាព ប្រសិទ្ធភាព និងផលិតភាពការងារខ្ពស់ ធានាបាននូវបណ្តុះបណ្តាល់សេវាកម្ម អប់រំ បណ្តុះបណ្តាល ប្រកបដោយ គុណភាពខ្ពស់បំផុត ។

៣- បន្តអភិវឌ្ឍ និងធ្វើបច្ចុប្បន្នកម្មនូវគោលការណ៍ប្រតិបត្តិ និងនីតិវិធីគ្រប់គ្រងកិច្ចការជំនាញទាំងអស់ ដើម្បីត្រៀមអនុវត្តផែនការកម្លាយខ្លួនទៅជាគ្រឹះស្ថានឧត្តមសិក្សា និងស្របតាមវិវឌ្ឍនាការថ្មីៗរបស់ក្រុមហ៊ុនមេ និងដើម្បីធានាបាននូវ តម្លាភាព អនុលោមភាព ឯកភាពនៃបទដ្ឋានការងារ អំណាចការងារ និងបង្ការបានជាអតិបរមានូវហានិភ័យទាំងឡាយ ។

៤- ចាត់ចែងធនធានមនុស្ស មូលដ្ឋានសម្ភាររូបវន្ត និងឧបទេស កម្មវិធីសិក្សា និងបច្ចេកទេស ឱ្យបានគ្រប់គ្រាន់ ទាន់ពេល និងប្រកបដោយគុណភាព ដើម្បីគាំទ្រដល់ដំណើរការកម្លាយខ្លួនទៅជា គ្រឹះស្ថានឧត្តមសិក្សាឱ្យប្រព្រឹត្តទៅដោយរលូន និងដើម្បីទទួលបាននូវភាពទាក់ទាញ និងទំនុកចិត្តពីគ្រប់មជ្ឈដ្ឋាន ជាពិសេសការចូលរួមពីភាគទុនិកអន្តរជាតិល្បីៗ ។

៥- បន្តចូលរួមអភិវឌ្ឍន៍កម្មវិធីហ្វឹកហ្វឺនឱ្យមានគុណភាពខ្ពស់ និងទាន់សម័យ ដើម្បីធានាបាននូវគុណភាពនៃការហ្វឹកហ្វឺន និងឧត្តមភាពការងារ ឆ្លើយតបទៅនឹងតម្រូវការ និងការវិវឌ្ឍន៍ថ្មីៗរបស់ក្រុមហ៊ុនមេ និងបុត្រសម្ព័ន្ធផ្សេងទៀត ក្នុងការអភិវឌ្ឍធនធានមនុស្ស ឱ្យមានសមត្ថភាពខ្ពស់ ដើម្បីបន្តផ្តល់នូវបទដ្ឋានសេវាកម្មកម្រិតខ្ពស់បំផុតជូនដល់អតិថិជន ។

៦- ជំរុញការបណ្តុះបណ្តាល បំពាក់បំប៉នវិធីសាស្ត្រ និងបច្ចេកទេសក្នុងការបង្រៀនដល់គ្រូហ្វឹកហ្វឺនទាំងអស់របស់ អេស៊ីលីដា ត្រេននីង សេនធ័រ និងក្រុមហ៊ុនមេជាប្រចាំ ដើម្បីធានាបាននូវគុណភាព និងប្រសិទ្ធភាពនៃការផ្ទេរ និងការទទួលចំណេះដឹង ជំនាញ និងរួមចំណែកដល់ការធ្វើឱ្យកាន់តែប្រសើរឡើងនូវអាកប្បកិរិយាជាវិជ្ជមានរបស់សិក្ខាកាម ។

៧- សហប្រតិបត្តិការជាមួយគ្រឹះស្ថានជាតិ និងអន្តរជាតិល្បីៗ លើការផ្លាស់ប្តូរកម្មវិធីសិក្សា, និស្សិត, សាស្ត្រាចារ្យ, ការសិក្សាស្រាវជ្រាវរួម... ដើម្បីចែករំលែកធនធាននិងបទពិសោធន៍ល្អៗ និងឈានទៅដល់ការធ្វើសកម្មភាពរួមគ្នា សម្រាប់ជាផលប្រយោជន៍ទៅវិញទៅមក ។

៨- សហការជាមួយបណ្តានិយោជកដែលកំពុងប្រើប្រាស់ ឬ ជ្រើសរើសសិក្ខាកាម និងនិស្សិត ដើម្បីសិក្សាស្វែងយល់ឱ្យបានស៊ីជម្រៅ អំពីតម្រូវការពិតប្រាកដនៅក្នុងទីផ្សារការងារ និងនិន្នាការទីផ្សារការងារសម្រាប់ជាមូលដ្ឋាន ក្នុងការអភិវឌ្ឍកម្មវិធីសិក្សាឱ្យមានគុណភាពខ្ពស់ និងទាន់សម័យ ឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារជាក់ស្តែង ។

៩- បង្កើនអត្រាទទួលបានការងារធ្វើរបស់និស្សិត ដែលបានបញ្ចប់ដោយជោគជ័យ ពីវគ្គបណ្តុះបណ្តាលជំនាញធនាគារខ្លីៗ សម្រាប់និស្សិតឱ្យបានជាអតិបរមា តាមរយៈការបន្តពង្រឹងលើ វិន័យសិក្សាល្អ ការអប់រំសីលធម៌ គុណភាព និងតម្លាភាព និងតាមរយៈការពង្រីកបណ្តាញទំនាក់ទំនង និងសហប្រតិបត្តិការ ជាមួយស្ថាប័នដៃគូដែលមានតម្រូវការជ្រើសរើសបុគ្គលិក ។

១០-បង្កើនការលក់សេវាហ្វឹកហ្វឺនដល់អតិថិជនខាងក្រៅ ដើម្បីទទួលបាននូវអត្រាប្រាក់ចំណូលដែលបានមកពីការហ្វឹកហ្វឺន និងបណ្តុះបណ្តាលសិក្ខាកាមមកពីខាងក្រៅ (ទាំងក្នុង និងក្រៅប្រទេស) រួមនឹងចំណូលផ្សេងៗ ធៀបនឹងចំណូលដុល ធំជាង ២៦% ។

១១-បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងចំណាយ កាត់បន្ថយនូវចំណាយមិនចាំបាច់ តាមរយៈការសន្សំសំចៃការប្រើប្រាស់ឧបករណ៍ និងសម្ភារទូទៅ ដើម្បីរក្សាបាននូវ អនុបាតប្រសិទ្ធភាពប្រតិបត្តិការឱ្យនៅក្រោម ៤២% ។

ជាចុងបញ្ចប់ យើងខ្ញុំសូមសម្តែងនូវគារវកិច្ច និងកតញ្ញូយ៉ាងជ្រាលជ្រៅ ចំពោះអតិថិជនដ៏ឆ្លាតវៃ ក្រុមហ៊ុនមេ ក្រុមប្រឹក្សាភិបាល ក្រុមប្រឹក្សាយោបល់ថ្នាក់គ្រប់គ្រង សាស្ត្រាចារ្យ និងបុគ្គលិកគ្រប់ជាន់ថ្នាក់ ព្រមទាំងដៃគូជាតិ និងអន្តរជាតិ និងជាពិសេសរាជរដ្ឋាភិបាលកម្ពុជា ដែលបានផ្តល់ទំនុកចិត្ត និងផ្តល់ការគាំទ្រយ៉ាងកក់ក្តៅដល់ អេស៊ីលីដា ត្រេននីង សេនធ័រ ក្នុងបេសកកម្មបណ្តុះបណ្តាលធនធានមនុស្សកន្លងមក។ យើងខ្ញុំសូមបួងសួងឱ្យលោកអ្នក និងក្រុមគ្រួសារទទួលបាននូវសេចក្តីសុខកាយ សប្បាយចិត្ត ចម្រើនដោយប្រយោជន៍ ជោគជ័យក្នុងនាទីការងារ និងមុខជំនួញ ប្រកបដោយគុណភាព និងប្រសិទ្ធភាពដ៏ឧត្តុង្គឧត្តម កុំបីឃ្លៀងឃ្លាតឡើយ ។




លោក ឆន ពន្លឺ

*អគ្គនាយក*

ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៥




អគ្គនាយក និងនាយកការិយាល័យទំនាក់ទំនងសាធារណៈ
ចូលរួម IFC's 6th International Private Education Conference in San Francisco



ប្រធានក្រុមប្រឹក្សាភិបាល និងអគ្គនាយក អេស៊ីលីដា ត្រេននីង សេនធ័រ
ធ្វើទស្សនកិច្ចនៅ Chaoyang University of Technology កោះតៃវ៉ាន់

# អង្គការលេខ


ភាគទុនិក
Shareholders
ក្រុមប្រឹក្សាភិបាល
Board of Directors
គណៈកម្មាធិការសិក្សាធិការ
Academic Committee
គណៈកម្មាធិការធានាគុណភាព
Quality Assurance Committee
ទីប្រឹក្សា
Advisor
អគ្គនាយក
President & CEO
អគ្គនាយករង
Vice-President & DCEO
ការិយាល័យ ទំនាក់ទំនងសាធារណៈ
Public Relation Department
ផ្នែកទីផ្សារ
Marketing Unit
ផ្នែកទំនាក់ទំនង និង សហប្រតិបត្តិការ
Customer Relation & Cooperation Unit
ដេប៉ាតឺម៉ង់ គ្រប់គ្រងពាណិជ្ជកម្ម
Department of Business Administration
សាស្ត្រាចារ្យជាន់ខ្ពស់
Senior Faculty
ការិយាល័យ សិក្សា និងកិច្ចការនិស្សិត
Academic & Student Affairs Department
ផ្នែកហ្វឹកហ្វឺនខាងក្រៅ និង កិច្ចការនិស្សិត
External Training & Student Affairs Unit
ផ្នែកហ្វឹកហ្វឺនខាងក្នុង
Internal Training Unit
ការិយាល័យ ស្រាវជ្រាវ និងអភិវឌ្ឍន៍
Research & Development Department
ផ្នែកស្រាវជ្រាវ
Research Unit
ផ្នែកអភិវឌ្ឍន៍ហ្វឹកហ្វឺន
Training Development Unit
ការិយាល័យ ផែនការ និងហិរញ្ញវត្ថុ
Planning & Finance Department
ផ្នែកគណនេយ្យគ្រប់គ្រង
Management Accounting Unit
ផ្នែកគណនេយ្យហិរញ្ញវត្ថុ
Financial Accounting Unit
ការិយាល័យ បុគ្គលិក និងរដ្ឋបាល
Personnel & Administration Department
ផ្នែកបុគ្គលិក
Personnel Unit
ផ្នែករដ្ឋបាល
Administration Unit
ផ្នែកសវនកម្មផ្ទៃក្នុង
Internal Audit Unit

# ភាគទុនិក

អេស៊ីលីដា ត្រេននីង សេនធ័រ ជាសហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត ដែលបានចុះបញ្ជីពាណិជ្ជកម្មដោយគោរពទៅតាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា ។ អេស៊ីលីដា ត្រេននីង សេនធ័រ មានការិយាល័យស្ថិតនៅអាគារលេខ៥០ ផ្លូវលេខ៥១៦ កែង៣៣៥ ភូមិ៦ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ និងមានភាគទុនិកកាន់កាប់ភាគហ៊ុន ១០០ ភាគរយ ដោយធនាគារ អេស៊ីលីដា ភីអិលស៊ី ជាក្រុមហ៊ុនមេ តំណាងដោយលោកបណ្ឌិត អ៊ិន ចាន់នី ។

ភាគទុនិក គឺជាម្ចាស់របស់ អេស៊ីលីដា ត្រេននីង សេនធ័រ ។ ភាគទុនិកមានសិទ្ធិអនុម័តលើយុទ្ធសាស្ត្រនានា ប៉ុន្តែភាគទុនិកពុំមានសិទ្ធិអំណាចគ្រប់គ្រងផ្ទាល់លើការងារទាំងអស់នេះទេ ទោះបីជាយ៉ាងណាក៏ដោយ ភាគទុនិកអាចផ្ទេរការទទួលបន្ទុកទាំងនេះទៅឱ្យក្រុមប្រឹក្សាភិបាល តាមរយៈអនុស្សរណៈ និងលក្ខន្តិកៈរបស់ អេស៊ីលីដា ត្រេននីង សេនធ័រ ។

## ធនាគារ អេស៊ីលីដា ភីអិលស៊ី

ធនាគារ អេស៊ីលីដា ភីអិលស៊ី ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដែលបានបង្កើតឡើង តាមប្រព័ន្ធច្បាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា ។ ធនាគារ អេស៊ីលីដា បានចាប់បដិសន្ធិឡើងនៅក្នុងខែមករា ឆ្នាំ១៩៩៣ ក្នុងនាមជាអង្គការក្រៅរដ្ឋាភិបាលមួយ ដែលមានទិសដៅអភិវឌ្ឍន៍មុខរបរខ្នាតតូចបំផុត និងខ្នាតតូច តាមរយៈការផ្តល់ឥណទាន ។

នៅថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០០ ធនាគារ អេស៊ីលីដា បានទទួលអាជ្ញាប័ណ្ណជាធនាគារឯកទេសពីធនាគារជាតិនៃកម្ពុជា ។ នៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៣ ធនាគារ អេស៊ីលីដា បានទទួលអាជ្ញាប័ណ្ណជាធនាគារពាណិជ្ជពីធនាគារជាតិនៃកម្ពុជា ដែលធ្វើឱ្យធនាគារ អេស៊ីលីដា មានលទ្ធភាពបំពេញទៅតាមតម្រូវការរបស់អតិថិជននូវសេវាធនាគារបានទូទៅ និងទូលំទូលាយថែមទៀត ហើយក៏បានប្តូរឈ្មោះជាផ្លូវការមកជា "ធនាគារ អេស៊ីលីដា ភីអិលស៊ី" ។

នៅចុងខែធ្នូ ឆ្នាំ២០១៤ ធនាគារ អេស៊ីលីដា មានបណ្តាញប្រតិបត្តិការចំនួន ២៥៣ សាខា កម្មករនិយោជិតចំនួន ១១.១៨២នាក់ និងមានទ្រព្យសកម្មសរុបចំនួន ៣.០៥២ លានដុល្លារអាមេរិក ។

ព័ត៌មានបន្ថែមសូមចូលទស្សនាគេហទំព័រ: www.acledabank.com.kh



គណៈប្រតិភូជាន់ខ្ពស់ក្រសួងហិរញ្ញវត្ថុនៃប្រទេសមីយ៉ាន់ម៉ា
ទស្សនកិច្ចសិក្សាស្វែងយល់ពីការរីកចម្រើនរបស់ ធនាគារ អេស៊ីលីដា ភីអិលស៊ី



**បណ្ឌិត អ៊ិន ចាន់នី**

តំណាងភាគទុនិក

ជនជាតិខ្មែរ កើតក្នុងខែមិថុនា ឆ្នាំ១៩៦០ ។ លោកបណ្ឌិតបានចូលរួមក្នុងក្រុមប្រឹក្សាភិបាលនៅខែកញ្ញា ឆ្នាំ២០១៤ ។ បណ្ឌិត អ៊ិន ចាន់នី ជាសហស្ថាបនិក របស់អេស៊ីលីដា តាំងពីខែមករា ឆ្នាំ១៩៩៣ ។ ក្នុងតួនាទីជាប្រធាននាយកប្រតិបត្តិ លោកបណ្ឌិតជាអ្នកដឹកនាំគណៈកម្មាធិការប្រតិបត្តិ ទទួលខុសត្រូវរៀបចំផែនការយុទ្ធសាស្ត្ររួម និងដំណើរការងារអាជីវកម្មប្រចាំថ្ងៃរបស់ធនាគារ ព្រមទាំងប្រតិបត្តិផែនការអាជីវកម្ម ។ លោកបណ្ឌិត ទទួលខុសត្រូវផ្ទាល់ចំពោះក្រុមប្រឹក្សាភិបាល ។

ទំនួលខុសត្រូវផ្សេងទៀតរបស់លោកបណ្ឌិត រួមមាន ៖ ជាប្រធានក្រុមប្រឹក្សាភិបាលធនាគារ អេស៊ីលីដា ឡាវ ព្រមទាំងតំណាងភាគទុនិកធនាគារ អេស៊ីលីដា ឡាវ, អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី, អេស៊ីលីដា ត្រេននីង សេនធ័រ, និងស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា ។

ក្រៅពីមុខងារ និងតួនាទីនៅធនាគារ អេស៊ីលីដា លោកបណ្ឌិតគឺជាសហប្រធានក្រុមការងារវិស័យឯកជននៃរាជរដ្ឋាភិបាល លើវិស័យធនាគារ និងហិរញ្ញវត្ថុ, អនុប្រធានសភាពាណិជ្ជកម្មអន្តរជាតិនៃកម្ពុជា (IBC), សមាជិកគណៈកម្មាធិការឥណទានសម្រាប់អភិវឌ្ឍន៍ជនបទ (CCRD), និងសមាជិកអនុគណៈកម្មាធិការរាជរដ្ឋាភិបាលសម្រាប់អភិបាលកិច្ចសាជីវកម្ម ។

បណ្ឌិត អ៊ិន ចាន់នី បច្ចុប្បន្នក៏ជាប្រធានសមាគមធនាគារអាស៊ាន និងជាប្រធានសមាគមធនាគារនៅកម្ពុជា ។

លោកបានបញ្ចប់ការសិក្សាថ្នាក់បណ្ឌិត ផ្នែកគ្រប់គ្រងអាជីវកម្ម និងបានបញ្ចប់វគ្គសិក្សាស្តីពី អភិបាលក្រុមហ៊ុន ពីវិទ្យាស្ថានអូស្ត្រាលីសម្រាប់អភិបាលក្រុមហ៊ុន (GAICD) ។

# ក្រុមប្រឹក្សាភិបាល

សមាជិក-សមាជិកាក្រុមប្រឹក្សាភិបាល ត្រូវតែងតាំងដោយតំណាងភាគទុនិក សម្រាប់អាណត្តិបី(៣)ឆ្នាំ ដើម្បីធ្វើសកម្មភាពតំណាងឱ្យភាគទុនិក ។ តាមលក្ខន្តិកៈបានបញ្ជាក់ថាសមាសភាពក្រុមប្រឹក្សាភិបាល ត្រូវមានយ៉ាងតិចបី(៣)រូប និង ៖

- ក្រុមប្រឹក្សាភិបាល ទទួលខុសត្រូវកំណត់យុទ្ធសាស្ត្ររបស់ អេស៊ីលីដា ត្រេននីង សេនធ័រ និងដឹកនាំត្រួតពិនិត្យដំណើរការកិច្ចការអាជីវកម្ម ។ សមាជិក-សមាជិកាក្រុមប្រឹក្សាភិបាល ត្រូវធ្វើកិច្ចការណាដែលផ្តល់ផលប្រយោជន៍ខ្ពស់បំផុតដល់អេស៊ីលីដា ត្រេននីង សេនធ័រ ។
- អំណាចរបស់ក្រុមប្រឹក្សាភិបាលត្រូវអនុវត្តរួមគ្នា ហើយគ្មានសមាជិក-សមាជិកាក្រុមប្រឹក្សាភិបាលណាម្នាក់ មានអំណាចចាត់ចែងមន្ត្រី ឬនិយោជិតរបស់ អេស៊ីលីដា ត្រេននីង សេនធ័រ ចុះហត្ថលេខាលើកិច្ចសន្យាណាមួយ ឬចាត់ចែងប្រតិបត្តិការរបស់ អេស៊ីលីដា ត្រេននីង សេនធ័រ លុះត្រាតែបានទទួលអំណាចពិសេស ដើម្បីចាត់ចែងទៅតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ។
- សមាជិក-សមាជិកាក្រុមប្រឹក្សាភិបាលម្នាក់ៗ អាចពិនិត្យមើលដោយគ្មានកម្រិតនូវបញ្ជី ឬបាយការណ៍របស់ អេស៊ីលីដា ត្រេននីង សេនធ័រ នៅក្នុងពេលម៉ោងធ្វើការធម្មតា ។

ក្រុមប្រឹក្សាភិបាលទាំងអស់ ត្រូវជ្រើសតាំងក្នុងចំណោមសមាជិក-សមាជិការបស់ខ្លួនមួយ(១)រូប ដើម្បីធ្វើជាប្រធានដោយសម្លេងឆ្នោតគាំទ្រភាគច្រើន ។ ប្រធានក្រុមប្រឹក្សាភិបាលជាអ្នកដឹកនាំរាល់កិច្ចប្រជុំក្រុមប្រឹក្សាភិបាល ។ សម្លេងឆ្នោតគាំទ្រភាគច្រើន នៃសមាជិក-សមាជិកាក្រុមប្រឹក្សាភិបាល ដែលកំពុងបម្រើការងារនៅការិយាល័យ អាចផ្លាស់ប្តូរប្រធានក្រុមប្រឹក្សាភិបាលបាន ប៉ុន្តែមិនអាចដកហូតតួនាទីជាសមាជិក-សមាជិកាក្រុមប្រឹក្សាភិបាលបានឡើយ ។

សមាជិក-សមាជិកាក្រុមប្រឹក្សាណាម្នាក់ ដែលមានផលប្រយោជន៍ហិរញ្ញវត្ថុទោះផ្ទាល់ ឬដោយប្រយោលក៏ដោយ ឬបើមានសមាជិកក្រុមគ្រួសារផ្ទាល់មានផលប្រយោជន៍បែបនេះ មុនពេលក្រុមប្រឹក្សាភិបាលធ្វើការសម្រេចលើសំណើណាក៏ដោយ សមាជិក-សមាជិកាក្រុមប្រឹក្សារូបនោះ ត្រូវតែជម្រាបសមាជិក-សមាជិកាក្រុមប្រឹក្សាដទៃទៀត ពីផលប្រយោជន៍នោះ មុនពេលអង្គប្រជុំក្រុមប្រឹក្សាភិបាលធ្វើការអនុម័ត ហើយសមាជិក-សមាជិកាក្រុមប្រឹក្សារូបនោះ មិនត្រូវចូលរួមពិភាក្សាលើសំណើនោះទេ លុះត្រាណាតែតម្រូវឱ្យចូលរួមពិភាក្សាដោយមានសម្លេងឆ្នោតគាំទ្រភាគច្រើន ពីសមាជិក-សមាជិកាក្រុមប្រឹក្សាដទៃទៀត ដែលចូលរួមក្នុងអង្គប្រជុំនោះ ។ សមាជិក-សមាជិកាក្រុមប្រឹក្សារូបនោះមិនត្រូវបោះឆ្នោតលើករណីបែបនោះទេ ប៉ុន្តែវត្តមានរបស់សមាជិក-សមាជិកាក្រុមប្រឹក្សារូបនោះអាចរាប់បញ្ចូលក្នុងកូរ៉ុមនៃអង្គប្រជុំ ។

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវលើអភិបាលកិច្ចសាជីវកម្ម និងការជំរុញអភិវឌ្ឍន៍ជោគជ័យរបស់ អេស៊ីលីដា ត្រេននីង សេនធ័រ ។ ក្រុមប្រឹក្សាភិបាលជាអ្នកតែងតាំងអគ្គនាយក សម្រាប់ដឹកនាំកិច្ចការ អេស៊ីលីដា ត្រេននីង សេនធ័រ និងអាចដកតំណែងអគ្គនាយកវិញបាន ។

ក្រុមប្រឹក្សាភិបាលអាចបង្កើតគណៈកម្មាធិការនានា ដែលយល់ថាចាំបាច់ក្នុងការដឹកនាំកិច្ចការជំនួញ និងប្រតិបត្តិការរបស់ អេស៊ីលីដា ត្រេននីង សេនធ័រ ។ គណៈកម្មាធិការទាំងនេះបង្កើតឡើងតាមឆន្ទៈរបស់ក្រុមប្រឹក្សាភិបាល ហើយសមាជិក-សមាជិកាទាំងអស់នៃគណៈកម្មាធិការទាំងនេះ ត្រូវតែអនុវត្តទៅតាមឆន្ទៈរបស់ក្រុមប្រឹក្សាភិបាល ។



ក្រុមប្រឹក្សាភិបាល អេស៊ីលីដា ត្រេននីង សេនធ័រ

## ក្រុមប្រឹក្សាភិបាល



### បណ្ឌិត សូ ផនណារី
ប្រធានក្រុមប្រឹក្សាភិបាល

ជនជាតិខ្មែរ កើតក្នុងខែវិច្ឆិកា ឆ្នាំ១៩៦៣ និងចូលបម្រើការនៅអេស៊ីលីដា ចាប់តាំងពីថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៩៣ ។ ក្នុងមុខតំណែងជាអនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយិកាប្រតិបត្តិប្រតិបត្តិការ លោកស្រីបណ្ឌិតក៏ជាសមាជិកាគណៈកម្មាធិការប្រតិបត្តិ ទទួលបន្ទុកដឹកនាំលើប្រតិបត្តិការរបស់ធនាគារ និងគ្រប់គ្រងនាយកដ្ឋានប្រតិបត្តិការ, នាយកដ្ឋានទីផ្សារ, នាយកដ្ឋានអភិវឌ្ឍន៍ផលិតផល, នាយកដ្ឋានឥណទាន, នាយកដ្ឋានហិរញ្ញប្បទានពាណិជ្ជកម្ម, នាយកដ្ឋានសេវាឥណទាន, និងការិយាល័យប្រតិបត្តិ ។ លោកស្រីបណ្ឌិតទទួលបន្ទុកគ្រប់គ្រងផែនការយុទ្ធសាស្រ្ត និងប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃរបស់ធនាគារ ដោយផ្តោតទៅលើផែនការយុទ្ធសាស្រ្តលក់ផលិតផល និងសេវាកម្មដែលមានស្រាប់ និងថ្មីៗ ។ លោកស្រីបណ្ឌិតទទួលខុសត្រូវ ទៅលើការដឹកនាំ ត្រួតពិនិត្យនិងវាយតម្លៃលើប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃ របស់ធនាគារ ។ លើសពីនេះលោកស្រីបណ្ឌិត ក៏ជាសមាជិកា គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងអកម្ម, គណៈកម្មាធិការកំណត់ថ្លៃផលិតផល និងសេវាកម្ម, និងគណៈកម្មាធិការឥណទាននៃថ្នាក់គ្រប់គ្រង ។ លោកស្រីបណ្ឌិតទទួលខុសត្រូវដោយផ្ទាល់ចំពោះប្រធាននាយកប្រតិបត្តិ ។

ទំនួលខុសត្រូវផ្សេងទៀត របស់លោកស្រីបណ្ឌិត ជាប្រធានក្រុមប្រឹក្សាភិបាល អេស៊ីលីដា ត្រេននីង សេនធ័រ ។ លោកស្រីបានបញ្ចប់ថ្នាក់បណ្ឌិត ផ្នែកគ្រប់គ្រងធុរកិច្ច ។

### លោក ព្រំ ទិសុទ្ធ
អភិបាល

ជនជាតិខ្មែរ កើតក្នុងខែមករា ឆ្នាំ១៩៧៥ និងបានបម្រើការនៅអេស៊ីលីដា ចាប់តាំងពីខែមិថុនា ឆ្នាំ១៩៩៨ ។ ក្នុងមុខតំណែងជាអនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិនីតិកម្ម និងលេខាធិការក្រុមហ៊ុន លោកក៏ជាសមាជិកគណៈកម្មាធិការប្រតិបត្តិ ទទួលបន្ទុកគ្រប់គ្រងផែនការយុទ្ធសាស្រ្តរួម និងប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃរបស់ធនាគារ ដោយអនុលោមទៅតាមបទបញ្ញត្តិព្រមទាំងទំនាក់ទំនងជាមួយភាគទុនិក និងក្រុមប្រឹក្សាភិបាល ។ លោកជាប្រធានគណៈកម្មាធិការលទ្ធកម្មនៃថ្នាក់គ្រប់គ្រង, ជាប្រធានគម្រោងសាងសង់អគារការិយាល័យកណ្តាលថ្មីបន្ថែម និងជាសមាជិកគណៈកម្មាធិការឥណទាននៃថ្នាក់គ្រប់គ្រង ។ លោកទទួលបន្ទុកគ្រប់គ្រងលើ ការិយាល័យនីតិកម្ម, ការិយាល័យវិវាទ, ការិយាល័យប្រតិបត្តិនីតិកម្ម, ការិយាល័យលេខាធិការក្រុមហ៊ុន, និងការិយាល័យពិធីការ ។ លោកទទួលខុសត្រូវដោយផ្ទាល់ ចំពោះប្រធាននាយកប្រតិបត្តិ ។

ទំនួលខុសត្រូវផ្សេងទៀតរបស់លោក រួមមាន៖ ជាសមាជិកក្រុមប្រឹក្សាភិបាល អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី, និងអេស៊ីលីដា ត្រេននីង សេនធ័រ ។

លោកបានបញ្ចប់ការសិក្សា ថ្នាក់អនុបណ្ឌិតគ្រប់គ្រងអាជីវកម្ម ជំនាញហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យ Charles Sturt ប្រទេសអូស្រ្តាលី ។

### បណ្ឌិត អ៊ុង សំអុល
អភិបាល

ជនជាតិខ្មែរ កើតឆ្នាំ១៩៦៣ បានទទួលសញ្ញាបត្របណ្ឌិតស្រាវជ្រាវ ឯកទេសវិទ្យាសាស្រ្តសេដ្ឋកិច្ច នៅសាកលវិទ្យាល័យបៀលប្រាយ រាជធានីភ្នំពេញ ក្នុងឆ្នាំ២០១៣ ។ លោកបានទទួលបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអាជីវកម្ម ជំនាញគណនេយ្យ និងហិរញ្ញវត្ថុ នៅសាកលវិទ្យាល័យបៀលប្រាយ រាជធានីភ្នំពេញ ក្នុងឆ្នាំ២០០៥ ។ លោកបានបញ្ចប់បរិញ្ញាបត្រសេដ្ឋកិច្ច ជំនាញធនាគារ និងហិរញ្ញវត្ថុ នៅសាកលវិទ្យាល័យន័រតុន រាជធានីភ្នំពេញ ក្នុងឆ្នាំ២០០១ ។ លោកបានទទួលសញ្ញាបត្រគណនេយ្យ និងហិរញ្ញវត្ថុនៅសាលាពាណិជ្ជកម្មភ្នំពេញ ក្នុងឆ្នាំ១៩៨៨ ។ លោកបានបម្រើការងារឱ្យ អេស៊ីលីដា ក្នុងតួនាទីជាគណនេយ្យករ នៅឆ្នាំ១៩៩៨ បន្ទាប់មកត្រូវបានតែងតាំងជាប្រធានផ្នែកត្រួតពិនិត្យឥណទាននៃនាយកដ្ឋានឥណទាន នៅក្នុងឆ្នាំ១៩៩៩ ។ លោកបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលផ្នែកគ្រប់គ្រង និងគណនេយ្យជាច្រើននៅក្នុងប្រទេសកម្ពុជា ។ នៅឆ្នាំ២០០១ លោកត្រូវបានតែងតាំងជា នាយក ធនាគារ អេស៊ីលីដា សាខាខេត្តកំពង់ធំ ជានាយករងនាយកដ្ឋានប្រតិបត្តិការនៅការិយាល័យកណ្តាលក្នុងឆ្នាំ២០០៤ ជានាយកនាយកដ្ឋានហិរញ្ញប្បទានពាណិជ្ជកម្ម នៅខែមករា ឆ្នាំ២០០៦ និងជានាយកប្រតិបត្តិហិរញ្ញប្បទានពាណិជ្ជកម្មពីខែកក្កដា ឆ្នាំ២០០៦រហូតដល់បច្ចុប្បន្ន ។ លោកបណ្ឌិត អ៊ុង សំអុល បានក្លាយជាសមាជិកនៃក្រុមប្រឹក្សាភិបាល អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី ក្នុងខែ មីនា ឆ្នាំ២០១១ និងត្រូវបានតែងតាំងជាសមាជិកក្រុមប្រឹក្សាភិបាល អេស៊ីលីដា ត្រេននីង សេនធ័រ ក្នុងខែសីហា ឆ្នាំ២០១៣ ។

# គណៈកម្មាធិការប្រតិបត្តិ

អគ្គនាយក ត្រូវបានតែងតាំងឡើងដោយក្រុមប្រឹក្សាភិបាល ដើម្បីទទួលខុសត្រូវលើការគ្រប់គ្រងដំណើរការអាជីវកម្មប្រចាំថ្ងៃរបស់ អេស៊ីលីដា ត្រេននីង សេនធ័រ នៅក្នុងរង្វង់គោលការណ៍ និងយុទ្ធសាស្ត្រ ដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល ។ ប៉ុន្តែកិច្ចការជាក់លាក់មួយចំនួនអាចត្រូវបានកំណត់ដោយក្រុមប្រឹក្សាភិបាល ។

អគ្គនាយក ជាអ្នកតែងតាំង និងដឹកនាំគណៈកម្មាធិការប្រតិបត្តិ ដែលរួមមានសមាសភាពនៃថ្នាក់ដឹកនាំជាន់ខ្ពស់ ដោយលោកយល់ឃើញថាសមស្រប (ករណីមានការផ្លាស់ប្តូរណាមួយ ត្រូវជូនដំណឹងទៅក្រុមប្រឹក្សាភិបាលឱ្យបានទាន់ពេលសមស្រប) ។ ភារកិច្ចទទួលខុសត្រូវ និងដំណើរការនៃគណៈកម្មាធិការប្រតិបត្តិនឹងត្រូវកំណត់ដោយអគ្គនាយក តាមការសម្រេចក្រោមចំណុចសំខាន់ៗទូទៅដូចជា ៖

- ទិសដៅយុទ្ធសាស្ត្រ ៖ អភិវឌ្ឍន៍គោលការណ៍ គោលដៅយុទ្ធសាស្ត្រ និងទិសដៅ សម្រាប់ក្រុមប្រឹក្សាភិបាលអនុម័ត ។
- ការអនុវត្ត ៖ ប្រមូលផ្តុំនូវរាល់ធនធាន ដើម្បីអនុវត្តតាមយុទ្ធសាស្ត្រ ដែលបានកំណត់ និងការប្រតិបត្តិតាមគោលដៅ ដែលបានអនុម័ត ។
- ហានិភ័យ ៖ កំណត់ និងវាយតម្លៃលើហានិភ័យ នៅក្នុងយុទ្ធសាស្ត្ររបស់ អេស៊ីលីដា ត្រេននីង សេនធ័រ និងចាត់ចែងបញ្ហាដែលកើតឡើង ។
- ការប្រតិបត្តិ ៖ ធានាថា អេស៊ីលីដា ត្រេននីង សេនធ័រ ប្រតិបត្តិអនុលោមទៅតាមតម្រូវការរបស់ សាជីវកម្ម ច្បាប់ និងបទប្បញ្ញត្តិទាំងអស់ ។



**លោក ឆន ពន្លឺ**

អគ្គនាយក

ជនជាតិខ្មែរ កើតក្នុងឆ្នាំ១៩៧៨, លោកបានបញ្ចប់ថ្នាក់អនុបណ្ឌិតគ្រប់គ្រងពាណិជ្ជកម្ម ជំនាញគ្រប់គ្រង ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង នៅក្នុងឆ្នាំ២០០៥ ។ នៅក្នុងឆ្នាំ១៩៩៩ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រគ្រប់គ្រងពាណិជ្ជកម្ម ជំនាញទីផ្សារ ពីមហាវិទ្យាល័យពាណិជ្ជសាស្ត្រ ដែលសហការកម្មវិធីសិក្សា ជាមួយ University of San Francisco របស់សហរដ្ឋអាមេរិក និង Georgetown University របស់ចក្រភពអង់គ្លេស ។ ចាប់ពីឆ្នាំ២០០៣ មកលោកបានបំពេញទស្សនកិច្ច និងចូលរួមវគ្គបណ្តុះបណ្តាលជាច្រើនទៀតទាំងនៅក្នុងប្រទេស និងពីបណ្តាប្រទេសមួយចំនួនដូចជាប្រទេស អាល្លឺម៉ង់ សហរដ្ឋអាមេរិក ហុងកុង ឥណ្ឌូនេស៊ី ចិន ហ្វីលីពីន ភូមា ឡាវ កោះតៃវ៉ាន់... ទាក់ទងនឹងការបណ្តុះបណ្តាលធនាគារ និងហិរញ្ញវត្ថុ, ការគ្រប់គ្រងកម្មវិធីបណ្តុះបណ្តាល, វគ្គបណ្តុះបណ្តាលជំនាញរៀបចំ និងអភិវឌ្ឍន៍កម្មវិធីសិក្សា, វគ្គបណ្តុះបណ្តាលគ្រូហ្វឹកហ្វឺន, វគ្គប្រឹក្សាយោបល់បែបវិជ្ជាជីវៈ, និងវគ្គបណ្តុះបណ្តាលជាច្រើនផ្សេងទៀត ។ នៅឆ្នាំ២០១៤ លោកបានបំពេញទស្សនកិច្ចសិក្សានៅសាកលវិទ្យាល័យមួយចំនួននៃកោះតៃវ៉ាន់ ដើម្បីស្វែងយល់អំពីប្រព័ន្ធគ្រប់គ្រងនៃការបណ្តុះបណ្តាល នៅថ្នាក់គ្រឹះស្ថានឧត្តមសិក្សា ។ នៅក្នុងឆ្នាំ២០១៣ លោកបានបំពេញទស្សនកិច្ចសិក្សានៅ Frankfurt School of Finance and Management ប្រទេសអាល្លឺម៉ង់ លើប្រធានបទ ការកម្លាយខ្លួនពីមជ្ឈមណ្ឌលហ្វឹកហ្វឺនធនាគារ ទៅជាសាលាពាណិជ្ជសាស្ត្រខ្នាតអន្តរជាតិ និងបានបំពេញទស្សនកិច្ចសិក្សានៅ Harvard Business School សហរដ្ឋអាមេរិក លើប្រធានបទការអភិវឌ្ឍទៅជាសាលាពាណិជ្ជសាស្ត្រខ្នាតអន្តរជាតិ ។

លោកបានចូលបម្រើការជាមួយ អេស៊ីលីដា មីក្រូហិរញ្ញវត្ថុ នៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៩៩ ក្នុងមុខដំណែងជាគណនេយ្យករ និងត្រូវបានដំឡើងមុខងារតួនាទីទៅជា ប្រធានគណនេយ្យករសាខា នៅក្នុងខែ កុម្ភៈ ឆ្នាំ២០០០ ។ ជាបន្តនៅក្នុងខែកុម្ភៈ ឆ្នាំ២០០៥ លោកត្រូវបានផ្លាស់ប្តូរមុខងារតួនាទីទៅជា ប្រធានទីផ្សារសាខា និងត្រូវបានដំឡើងមុខងារតួនាទីជានាយកសាខា ធនាគារ អេស៊ីលីដា ភីអិលស៊ី នៅក្នុងឆ្នាំ២០០៧ និងត្រូវបានផ្លាស់ប្តូរមុខតំណែងជា នាយកការិយាល័យបណ្តុះបណ្តាលមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា-អាស៊ាន នៅក្នុងឆ្នាំ២០០៩ ។ លោកបានទទួលមុខតំណែងជា អគ្គនាយក អេស៊ីលីដា ត្រេននីង សេនធ័រ ចាប់ពីខែសីហា ឆ្នាំ២០១១ រហូតមកដល់ពេលបច្ចុប្បន្ន ។



កិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិ អេស៊ីលីដា ត្រេននីង សេនធ័រ

## គណៈកម្មាធិការប្រតិបត្តិ



### លោក គូច ង៉ាមយ៉ូរ៉ា
### នាយកការិយាល័យទំនាក់ទំនងសាធារណៈ

ជនជាតិខ្មែរ កើតថ្ងៃទី២៧ ខែឧសភា ឆ្នាំ១៩៥៩។ លោកទទួលបានបរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកមនុស្សសាស្រ្ត និងវិទ្យាសាស្រ្តនយោបាយ ជំនាញរដ្ឋបាលសាធារណៈ ពីសាកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យា នៅរាជធានីភ្នំពេញ ក្នុងឆ្នាំ២០០៩។ លោកទទួលបាន វិញ្ញាបនបត្រកម្រិតស្មើ បរិញ្ញាបត្ររដ្ឋបាលសាធារណៈ នៅឆ្នាំ២០០៨ ពីសាកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យា ដែលបានទទួលស្គាល់ដោយគណៈកម្មការជ្រើសរើស និងវាយតម្លៃបទពិសោធន៍ការងារ មន្រ្តីរាជការវ័យចំណាស់ និងឥស្សរជន។ លោកធ្លាប់បាន ចូលរួមវគ្គហ្វឹកហ្វឺនខ្លីៗ និងទស្សនកិច្ចសិក្សាជាច្រើន ដូចជា៖ ទស្សនកិច្ចសិក្សាទៅកាន់ធនាគារ RAKYAT (BRI) ប្រទេសឥណ្ឌូនេស៊ី, វគ្គហ្វឹកហ្វឺន ស្តីពីការគ្រប់គ្រងស្ថាប័នមីក្រូហិរញ្ញវត្ថុ និងគរុកោសល្យវិទ្យាជាមួយ Frankfurt School of Finance & Management នៅប្រទេសអាល្លឺម៉ង់ និង Boulder Institute of Microfinance ITC-ILO នៅទីក្រុង Turin ប្រទេស អ៊ីតាលី ។

ចាប់ពីឆ្នាំ១៩៨២ ដល់១៩៩៧ លោកបានចាប់ផ្តើមអាជីពជា គណនេយ្យករ, ប្រធានបេឡាធិការ, ប្រធានគណនេយ្យករ នៅសាខាធនាគារជាតិស្រុកមង្គលបូរី ជាមន្រ្តីឥណទាន និងក្រោយមកជានាយឃ្លាំងប្រាក់ នៅសាខាធនាគារជាតិខេត្តបន្ទាយមានជ័យ។

មកដល់ថ្ងៃទី០២ ខែមករា ១៩៩៨ លោកបានចូលបម្រើការងារជាមួយ ធនាគារ អេស៊ីលីដា ដោយបានឆ្លងកាត់ មុខងារជា ភ្នាក់ងារឥណទាន, សវនករផ្ទៃក្នុង ហើយត្រូវបានតែងតាំងជា ប្រធានការិយាល័យស្រុកមង្គលបូរីនៅឆ្នាំ២០០២។ មកដល់ឆ្នាំ២០០៧ លោកត្រូវបានតែងតាំងជា សមាជិកនៃក្រុមអ្នកជំនាញការរៀបចំបង្កើត ធនាគារ អេស៊ីលីដា ឡាវ ចំកាត់ ក្នុងមុខតំណែងជានាយកសាខាទីក្រុងវៀងចាន់ សាធារណរដ្ឋប្រជាធិបតេយ្យ ប្រជាមានិតឡាវ ។ បន្ទាប់ពីបានបំពេញបេសកកម្មចប់ នៅឆ្នាំ២០០៩ លោកត្រូវបានប្តូរមុខងារជា ជំនួយការនាយកនាយកដ្ឋានហ្វឹកហ្វឺន ។ ចាប់តាំងពីឆ្នាំ២០១១ ដល់សព្វថ្ងៃលោកស្ថិតនៅក្នុងតំណែងជា នាយកការិយា-ល័យទំនាក់ទំនងសាធារណៈ នៃអេស៊ីលីដា ត្រេននីង សេនធ័រ ។

### លោក យ៉ាន់ យ៉េត
### នាយកដេប៉ាតឺម៉ង់ គ្រប់គ្រងពាណិជ្ជកម្ម

ជនជាតិខ្មែរ កើតឆ្នាំ១៩៨០ ។ លោកបានបញ្ចប់ថ្នាក់អនុបណ្ឌិត ផ្នែកគ្រប់គ្រងពាណិជ្ជកម្ម ជំនាញគ្រប់គ្រង ពីសាកលវិទ្យាល័យន័រតុន នៅក្នុងឆ្នាំ២០១០ ។ នៅក្នុងឆ្នាំ២០០៣ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រគ្រប់គ្រងពាណិជ្ជកម្ម ជំនាញគ្រប់គ្រង ពីវិទ្យាស្ថានជាតិគ្រប់គ្រង ហើយលោកបានទទួល សញ្ញាបត្រភាសាអង់គ្លេស ផ្នែកទំនាក់ទំនងពាណិជ្ជកម្ម ពីវិទ្យាស្ថានអប់រំ ពាណិជ្ជសាស្រ្ត នៅក្នុងឆ្នាំ២០១០ ។ ចាប់ពីឆ្នាំ២០០៤មក លោកធ្លាប់បានចូលរួមវគ្គ ទស្សនកិច្ចសិក្សា និងវគ្គបណ្តុះបណ្តាលជាច្រើន ទាំងនៅក្នុងប្រទេស និងក្រៅប្រទេស ដូចជា វគ្គបណ្តុះបណ្តាលធនាគារ និងហិរញ្ញវត្ថុ វគ្គបណ្តុះបណ្តាលជំនាញ គ្រូហ្វឹកហ្វឺន នៅប្រទេសហ្វីលីពីន វគ្គបណ្តុះបណ្តាល ជំនាញគ្រូហ្វឹកហ្វឺន និង ជំនាញអភិវឌ្ឍន៍វិជ្ជាជីវៈ នៅប្រទេសវៀតណាម វគ្គបណ្តុះបណ្តាល ជំនាញរៀបចំ និងអភិវឌ្ឍន៍កម្មវិធីហ្វឹកហ្វឺន នៅសៀងហៃ ប្រទេសចិន វគ្គបណ្តុះបណ្តាល ជំនាញប្រឹក្សាយោបល់បែបវិជ្ជាជីវៈ នៅហុងកុង ប្រទេសចិន វគ្គបណ្តុះបណ្តាលគ្រប់គ្រងហានិភ័យឥណទាន នៅប្រទេសម៉ាឡេស៊ី វគ្គបណ្តុះបណ្តាលគ្រូហ្វឹកហ្វឺន និងជំនាញគ្រប់គ្រងហានិភ័យ ជាមួយ Frankfurt School of Finance and Management ។

លោកបានចូលបម្រើការងារ ជាមួយធនាគារ អេស៊ីលីដា នៅក្នុងឆ្នាំ២០០៤ ក្នុងមុខដំណែងជាមន្រ្តីឥណទាន ហើយលោកត្រូវបានផ្លាស់ប្តូរមុខងារតួនាទីទៅជា ភ្នាក់ងារទីផ្សារ នៅក្នុងឆ្នាំ២០០៧ ។ នៅក្នុងឆ្នាំ២០០៨ លោកត្រូវបានតែងជា មន្រ្តីឥណទានសាជីវកម្ម ហើយបន្ទាប់មកលោកត្រូវបានជ្រើសរើស ដំឡើងមុខងារតួនាទីជាសាស្រ្តាចារ្យជាន់ខ្ពស់ នៃអេស៊ីលីដា ត្រេននីង សេនធ័រ នៅក្នុងឆ្នាំ២០០៩ ។ ចាប់ពីដើមឆ្នាំ២០១៤ មកដល់បច្ចុប្បន្ន លោកមានតួនាទីជា នាយកដេប៉ាតឺម៉ង់គ្រប់គ្រងពាណិជ្ជកម្ម នៃអេស៊ីលីដា ត្រេននីង សេនធ័រ ។

### លោកស្រី ទូត សុវណ្ណេ
### នាយិកាការិយាល័យសិក្សា និងកិច្ចការនិស្សិត

ជនជាតិខ្មែរ កើតក្នុងឆ្នាំ១៩៨០ លោកស្រីបានបញ្ចប់ ថ្នាក់អនុបណ្ឌិតគ្រប់គ្រងពាណិជ្ជកម្ម ជំនាញគ្រប់គ្រង ពីសាកលវិទ្យាល័យបញ្ញាសាស្រ្ត នៅក្នុងឆ្នាំ២០១៤ ។ នៅក្នុងឆ្នាំ២០០២ លោកស្រីបានបញ្ចប់ថ្នាក់បរិញ្ញាបត្រ អក្សរសាស្រ្តអង់គ្លេស ពីសាកលវិទ្យាល័យន័រតុន ។ លោកស្រីបានចូលរួម វគ្គហ្វឹកហ្វឺន និងវគ្គទស្សនកិច្ចសិក្សាជាច្រើនទៀត ទាំងក្នុង និងក្រៅប្រទេស ដូចជាប្រទេសហ្វីលីពីន ឥណ្ឌូណេស៊ី និង វៀតណាម ទាក់ទងនឹងវគ្គបណ្តុះបណ្តាលខាងវិស័យធនាគារ ជាមួយ AMiDA (Academy for Microfinance Development in Asia), វគ្គទស្សនកិច្ចសិក្សាស្តីពីការគ្រប់គ្រងកម្មវិធីបណ្តុះបណ្តាល ជាមួយ CARD MRI និងវគ្គបណ្តុះបណ្តាល ជំនាញគ្រូហ្វឹកហ្វឺន ជាមួយ Frankfurt School of Finance & Management និងRobenny School of Business ។

លោកស្រី បានចូលបម្រើការជាមួយ ធនាគារ អេស៊ីលីដា នៅក្នុងខែមីនា ឆ្នាំ២០០៤ ក្នុងមុខតំណែងជាបុគ្គលិកផ្នែកហ្វឹកហ្វឺន និងត្រូវតែងតាំងទៅជាអនុប្រធានផ្នែកកម្មសិក្សា នៅឆ្នាំ២០០៨ លោកស្រីត្រូវបានដំឡើងមុខងារជា ប្រធានផ្នែកកម្មសិក្សា នៅឆ្នាំ២០០៩ ។ ជាបន្តបានផ្លាស់ប្តូរមុខងាជាប្រធានផ្នែកអភិបាលហ្វឹកហ្វឺន នៅឆ្នាំ២០១១ បន្ទាប់មក ផ្លាស់ជាប្រធានផ្នែកហ្វឹកហ្វឺនខាងក្រៅ នៅឆ្នាំ២០១២ ។ ចាប់ពីខែមករា ឆ្នាំ២០១៤ មកដល់បច្ចុប្បន្ន លោកស្រី មានតួនាទីជា នាយិកាការិយាល័យសិក្សា និងកិច្ចការនិស្សិត នៃ អេស៊ីលីដា ត្រេននីង សេនធ័រ។

## គណៈកម្មាធិការប្រតិបត្តិ



### លោក សូ សុវណ្ណារ៉េត
### នាយកការិយាល័យស្រាវជ្រាវ និងអភិវឌ្ឍន៍

កើតខែមិថុនា ឆ្នាំ១៩៧៣, លោកបានទទួលសញ្ញាបត្រថ្នាក់អនុបណ្ឌិត ផ្នែកគ្រប់គ្រងអភិវឌ្ឍន៍ (MDM) ជំនាញគ្រប់គ្រង ពីសាកលវិទ្យាល័យន័រតុន នៅឆ្នាំ២០០៨ ។ លោកបានបញ្ចប់បរិញ្ញាបត្រផ្នែកគ្រប់គ្រង ជំនាញគ្រប់គ្រង ពីវិទ្យាស្ថានវិទ្យាសាស្ត្រគ្រប់គ្រង នៅឆ្នាំ២០០៤ និងសញ្ញាបត្រភាសាអង់គ្លេស ផ្នែកទំនាក់ទំនងពាណិជ្ជកម្ម ពីវិទ្យាស្ថានអប់រំពាណិជ្ជសាស្ត្រ (Institute for Business Education) ក្នុងឆ្នាំ២០១០ ។ នៅឆ្នាំ២០១៥ លោកទទួលបានសញ្ញាបត្រ Certified Expert in Risk Management ពីសាលា Frankfurt School of Finance and Management ប្រទេសអាល្លឺម៉ង់។ នៅក្នុងឆ្នាំ២០១១, លោកបានបញ្ចប់ វគ្គបណ្តុះបណ្តាល ការគ្រប់គ្រងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ នៅទីក្រុង Frankfurt ប្រទេសអាល្លឺម៉ង់ និង វគ្គបណ្តុះបណ្តាលគ្រូហ្វឹកហ្វឺន, វគ្គជំនាញរៀបចំនិងអភិវឌ្ឍន៍កម្មវិធីសិក្សា, និងវគ្គជំនាញប្រឹក្សាយោបល់បែបវិជ្ជាជីវៈ ជាមួយសាលា Robenny School of Business នៅប្រទេសចិន និងនៅទីក្រុងហុងកុង ។ ចាប់ពីឆ្នាំ១៩៩៤ លោកក៏បានចូលរួមវគ្គបណ្តុះបណ្តាលបណ្តាលជាច្រើនទៀតដូចជាៈ ជំនាញគ្រប់គ្រងឥណទាននិងការដោះស្រាយបំណុលជាមួយ MPDF, ជំនាញទីផ្សារជាមួយ CARE International នៅប្រទេសថៃ, វគ្គ Micro Banking System ជាមួយ ធនាគារ RAKYAT( BRI ) នៅប្រទេសឥណ្ឌូនេស៊ី, វគ្គជំនាញភ្នាក់ងារឥណទាន, វគ្គគ្រប់គ្រងសម្រាប់នាយករង និងប្រធានការិយាល័យស្រុក, វគ្គ Coaching for Success & Leadership Effectiveness. និងវគ្គ Advanced Training and Capacity Building Strategies និងវគ្គ Specialized MFISV Program on Training Management ។

លោកបានចូលបម្រើការងារជាមួយ ធនាគារអេស៊ីលីដា នៅឆ្នាំ១៩៩៤ ក្នុងតួនាទីជា មន្ត្រីឥណទាន និងមន្ត្រីទំនាក់ទំនង រវាងអង្គការពលកម្មអន្តរជាតិ និងអេស៊ីលីដា ហើយលោកត្រូវបានតែងតាំងជាប្រធានការិយាល័យស្រុកនៅ ឆ្នាំ១៩៩៧ ។ លោកត្រូវបានតែងតាំង ជាប្រធានផ្នែកហ្វឹកហ្វឺន នៅឆ្នាំ២០០៥ ដល់ខែមិថុនា ឆ្នាំ២០០៩ ហើយបន្ទាប់មកលោកក៏ត្រូវបានដំឡើងឋានៈ ជាជំនួយការនាយកប្រតិបត្តិហ្វឹកហ្វឺន នៅខែកក្កដា ឆ្នាំ២០០៩, និងត្រូវបានតែងតាំងជានាយកការិយាល័យសិក្សា ចាប់ពីខែសីហា ឆ្នាំ២០១១ ដល់ខែធ្នូ ឆ្នាំ២០១២ ។ នាពេលបច្ចុប្បន្ននេះ លោកមានតួនាទីជានាយកការិយាល័យស្រាវជ្រាវនិងអភិវឌ្ឍន៍ ។

### លោក ហាស់ សម្បត្តិ
### នាយកការិយាល័យបុគ្គលិក និងរដ្ឋបាល

ជនជាតិខ្មែរ កើតឆ្នាំ១៩៥៩ ។ លោកបានទទួលសញ្ញាបត្រភាសាអង់គ្លេស ពី Gwynedd-Mercy College ( USA ) ក្នុងឆ្នាំ១៩៨៧ ។ លោកក៏បានចូលរួមវគ្គបណ្តុះបណ្តាល ជំនាញគ្រប់គ្រងឥណទាន និងការដោះស្រាយបំណុល ជាមួយ Mekong Project Development Facility ( MPDF ) នៅក្នុងឆ្នាំ ២០០២ ។ នៅឆ្នាំ១៩៩៥ លោកបានចូលរួម វគ្គបណ្តុះបណ្តាលជំនាញទីផ្សារ ជាមួយ Care International នៅប្រទេសថៃ និងបានចូលរួមវគ្គបណ្តុះបណ្តាល Micro Banking System ជាមួយ ធនាគារ RAKYAT ( BRI ) នៅប្រទេសឥណ្ឌូណេស៊ី ក្នុងឆ្នាំ១៩៩៨ ។ ចាប់ពីឆ្នាំ១៩៩៤ មក លោកបានចូលរួមវគ្គបណ្តុះបណ្តាលផ្សេងៗជាច្រើនទៀត ទាំងនៅក្នុងប្រទេស និងក្រៅប្រទេស។

លោកបានចូលបម្រើការងារជាមួយ ធនាគារអេស៊ីលីដា នៅក្នុងខែកក្កដាឆ្នាំ១៩៩៤ ក្នុងតួនាទីជាមន្ត្រីឥណទាន ហើយលោកត្រូវបានតែងតាំងជាប្រធានការិយាល័យស្រុកនៅឆ្នាំ១៩៩៧ ។

នៅក្នុងឆ្នាំ១៩៩៨ លោកត្រូវបានតែងតាំងជានាយករងសាខា និងត្រូវបានតែងតាំងជានាយកសាខាក្នុងឆ្នាំ២០០១ ។ នៅឆ្នាំ២០០៨ លោកត្រូវបានតែងតាំងជា នាយកការិយាល័យគ្រប់គ្រងការិយាល័យកណ្តាល ។ នៅក្នុងឆ្នាំ២០១០ លោកត្រូវបានផ្លាស់មុខងារតួនាទី ទៅជានាយករងនាយកដ្ឋានរដ្ឋបាល។ ចាប់ពីខែកុម្ភៈ ឆ្នាំ២០១៣ មកដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ លោកមានតួនាទីជានាយកការិយាល័យហិរញ្ញវត្ថុនិងរដ្ឋបាលនៃអេស៊ីលីដា ត្រែននីង សេនធ័រ ។ ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៤ មកដល់បច្ចុប្បន្ន លោកមានតួនាទីជានាយកការិយាល័យបុគ្គលិក និងរដ្ឋបាលនៃអេស៊ីលីដា ត្រែននីង សេនធ័រ ។

### លោក ភិន វ៉ាន់ថាក់
### នាយកការិយាល័យផែនការ និងហិរញ្ញវត្ថុ

ជនជាតិខ្មែរ កើតថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៨០។ លោកទទួលបាន បរិញ្ញាបត្រផ្នែកគណនេយ្យពីវិទ្យាស្ថានបច្ចេកវិទ្យានិងគ្រប់គ្រង។ បច្ចុប្បន្នលោកកំពុងរៀបចំនិក្ខេបបទបញ្ចប់ការសិក្សា សម្រាប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងពាណិជ្ជកម្ម នៅសាកលវិទ្យាល័យមេគង្គកម្ពុជា។ នៅឆ្នាំ ២០១៥ លោកទទួលបានសញ្ញាបត្រ Certified Expert in Risk Management ពីសាលា Frankfurt School of Finance and Management ប្រទេសអាល្លឺម៉ង់។ លោកក៏បានចូលរួមវគ្គហ្វឹកហ្វឺនជាច្រើន ដូចជា៖ សិក្ខាសាលាស្តីពី Overview on CAS and CIFRS, ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ, វគ្គហ្វឹកហ្វឺនស្តីពីសារពើពន្ធ, ជំនាញការិយាល័យ, កិច្ចការរដ្ឋបាលនិងវគ្គបំពាក់បំប៉នផ្សេងៗទៀត។ លោកមានបទពិសោធន៍រយៈពេលជាង ១០ឆ្នាំ នៅក្នុងជំនាញគណនេយ្យ, គ្រប់គ្រងហិរញ្ញវត្ថុ និង ការហ្វឹកហ្វឺន ។

ក្នុងឆ្នាំ២០០៤ លោកបានចូលបម្រើការងារជាមួយ ធនាគារ អេស៊ីលីដា ក្នុងមុខងារជាគណនេយ្យករសាខា ហើយបន្ទាប់មកត្រូវបានតែងតាំងជា ប្រធានគណនេយ្យករសាខា ។ លោកបានផ្លាស់ប្តូរមកបម្រើការងារ ជាបុគ្គលិក នៅនាយកដ្ឋានហិរញ្ញវត្ថុ នៃធនាគារ អេស៊ីលីដា ការិយាល័យកណ្តាល ដែលនៅពេលនោះ លោកបានធ្វើជាគ្រូហ្វឹកហ្វឺន និងផ្តល់ការគាំទ្រផ្នែកបច្ចេកទេសលើការរៀបចំផែនការថវិកា ដល់ប្រធានគណនេយ្យករសាខា ។

ក្នុងខែសីហា ឆ្នាំ២០១១ លោកត្រូវបានផ្លាស់ប្តូរឱ្យមកបម្រើការងារនៅ អេស៊ីលីដា ត្រែននីង សេនធ័រ ក្នុងមុខតំណែង ជាប្រធានផ្នែកផែនការ និងហិរញ្ញវត្ថុ។ លោកជាគ្រូហ្វឹកហ្វឺន វគ្គបណ្តុះបណ្តាល និងចែករំលែកបទពិសោធន៍ សម្រាប់ស្ថាប័នខាងក្រៅ ។ ចាប់តាំងពីខែមករា ឆ្នាំ២០១៤ មកដល់បច្ចុប្បន្ន លោកមានតួនាទីជា នាយកការិយាល័យផែនការ និងហិរញ្ញវត្ថុ នៃអេស៊ីលីដា ត្រែននីង សេនធ័រ ។

# ទីប្រឹក្សា

ទីប្រឹក្សា នៃអេស៊ីលីដា ត្រេននីង សេនធ័រ មានកាតព្វកិច្ចបំពេញតួនាទីឱ្យអស់ពីសមត្ថភាព ដើម្បីចូលរួមត្រួតពិនិត្យកែតម្រូវ និងផ្តល់យោបល់ អភិវឌ្ឍធ្វើយ៉ាងណា ឱ្យសម្រេចនូវគោលដៅយុទ្ធសាស្រ្ត របស់ អេស៊ីលីដា ត្រេននីង សេនធ័រ មានដូចជា៖

- ផ្តល់ការប្រឹក្សាយោបល់លើការរៀបចំផែនការ និងយុទ្ធសាស្រ្តដើម្បីដំណើរការ អេស៊ីលីដា ត្រេននីង សេនធ័រ ជាស្ថាប័នបុត្រសម្ព័ន្ធ ធនាគារ អេស៊ីលីដា ភីអិលស៊ី ប្រកបអាជីវកម្មដាច់ដោយឡែកប្រកបដោយនិរន្តរភាព ។
- ផ្តល់ការប្រឹក្សាយោបល់ លើការងារបណ្តុះបណ្តាល គ្រប់គ្រងប្រតិបត្តិការ និងការងារទំនាក់ទំនងសាធារណៈ ដើម្បីប្រែក្លាយ អេស៊ីលីដា ត្រេននីង សេនធ័រ ទៅជាគ្រឹះស្ថានឧត្តមសិក្សាឈានមុខនៅក្នុងតំបន់ ។
- ផ្តល់ការបណ្តុះបណ្តាល ផ្ទេរបទពិសោធន៍ និងចំណេះដឹង ដល់អ្នកពាក់ព័ន្ធ ដើម្បីពង្រឹងសមត្ថភាព និងពង្រឹងប្រតិបត្តិការ អេស៊ីលីដា ត្រេននីង សេនធ័រ ។



## លោក ថោង ចាន់តារា
ទីប្រឹក្សា

ជនជាតិខ្មែរ កើតថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៦០ ។ លោកទទួលបានបរិញ្ញាបត្រអប់រំ នៅមហាវិទ្យាល័យ Advanced Education នៅប្រទេសថៃ ឆ្នាំ១៩៩២ ។ ចាប់ពីឆ្នាំ១៩៩៤មក លោកបានចូលរួមវគ្គបណ្តុះបណ្តាលជាច្រើន នៅក្នុងវិស័យ ធនាគារ មីក្រូហិរញ្ញវត្ថុ និងសហគ្រាសខ្នាតតូច និងមធ្យមនៅក្នុងប្រទេស និងនៅបណ្តាប្រទេសមួយចំនួនដូចជា៖ សហរដ្ឋអាមេរិក ថៃ ហុងកុង សិង្ហបុរី ហ្វីលីពីន ឥណ្ឌូណេស៊ី មីយ៉ាន់ម៉ា ឡាវ ។ ក្នុងឆ្នាំ១៩៩៩ លោកបានបញ្ចប់វគ្គគ្រប់គ្រង ស្តីពីស្ថាប័នហិរញ្ញវត្ថុសម្រាប់អភិវឌ្ឍន៍សហគ្រាសឯកជន(FIPED) នៅសាកលវិទ្យាល័យ Harvard សហរដ្ឋអាមេរិក។

ចាប់ពីឆ្នាំ១៩៩៤ លោកបានបម្រើការងារជាមួយ អង្គការ អេស៊ីលីដា ជាភ្នាក់ងារផ្សព្វផ្សាយសហគ្រាសខ្នាតតូច(SEPO) និងជាភ្នាក់ងារឥណទាន ។ ក្នុងឆ្នាំ១៩៩៥ លោកត្រូវបានតែងតាំងជា នាយករង អេស៊ីលីដា សាខាខេត្តបាត់ដំបង ។

នៅក្នុង១៩៩៧ លោកជានាយក អេស៊ីលីដា សាខាខេត្តកំពង់ធំ ។ ឆ្នាំ២០០១ លោកជាប្រធានផ្នែកធនធានមនុស្ស នៅការិយាល័យកណ្តាល ធនាគារ អេស៊ីលីដា ភីអិលស៊ី ។ ក្នុងឆ្នាំ២០០២ លោកជាប្រធានផ្នែកហ្វឹកហ្វឺន និងជានាយកការិយាល័យហ្វឹកហ្វឺន នៅឆ្នាំ២០០៦ ហើយលោកត្រូវបានតែងតាំងជា នាយកនាយកដ្ឋានហ្វឹកហ្វឺន ចាប់ពីឆ្នាំ២០០៩ ដល់ ខែកក្កដា ឆ្នាំ២០១១ ។ ចាប់ពីខែសីហា ឆ្នាំ២០១១ រហូតមកដល់បច្ចុប្បន្ន លោកមានតំណែងជា ទីប្រឹក្សា នៃអេស៊ីលីដា ត្រេននីង សេនធ័រ ។

## លោក ម៉ែន សុផល
ទីប្រឹក្សា

ជនជាតិខ្មែរ កើតថ្ងៃទី០១ ខែមករា ឆ្នាំ១៩៥៨។ លោកបានទទួល សញ្ញាបត្របណ្តុះបណ្តាលជំនាញគ្រូហ្វឹកហ្វឺន នៅឆ្នាំ២០១១ ពី Frankfurt School of Finance & Management សញ្ញាបត្របណ្តុះបណ្តាលជំនាញរៀបចំ និងអភិវឌ្ឍន៍កម្មវិធីហ្វឹកហ្វឺន នៅឆ្នាំ២០១១ ពី Robenny School of Business សញ្ញាបត្របណ្តុះបណ្តាលជំនាញ គ្រូហ្វឹកហ្វឺន នៅឆ្នាំ២០០៦ ពីACE, សញ្ញាបត្រវិជ្ជាគ្រូហ្វឹកហ្វឺនគ្រូ នៅឆ្នាំ១៩៨៩, សញ្ញាបត្រគរុកោសល្យនៅឆ្នាំ១៩៩០ ពីមជ្ឈមណ្ឌលហ្វឹកហ្វឺនគ្រូ នៅប្រទេសថៃ ។ លោកបានចូលរួមវគ្គបណ្តុះបណ្តាលជាច្រើន នៅក្នុងវិស័យ ធនាគារ មីក្រូហិរញ្ញវត្ថុ និងសហគ្រាសខ្នាតតូច និងមធ្យម នៅក្នុងប្រទេស និងនៅបណ្តាប្រទេសមួយចំនួនដូចជា ៖ នៅប្រទេសថៃ ចិន ឥណ្ឌូណេស៊ី ហ្វីលីពីន អ៊ីតាលី ។

លោកបានចូលបម្រើការងារជាមួយ ធនាគារ អេស៊ីលីដា នៅឆ្នាំ១៩៩៣ ជាភ្នាក់ងារផ្សព្វផ្សាយសហគ្រាសខ្នាតតូចនិងជាគ្រូហ្វឹកហ្វឺន។ ឆ្នាំ១៩៩៤ លោកបានផ្លាស់មកបំពេញការងារជា អ្នកឯកទេសសហគ្រាសខ្នាតមធ្យម និងក្រុមគាំទ្របច្ចេកទេស។ នៅឆ្នាំ១៩៩៨ លោកត្រូវបានតែងតាំងជា នាយកមជ្ឈមណ្ឌលហ្វឹកហ្វឺនអេស៊ីលីដា។ ឆ្នាំ២០០០ លោកត្រូវបានតែងតាំងជានាយករងនាយកដ្ឋានឥណទាន។ ចាប់តាំងពីឆ្នាំ២០០១មក លោកត្រូវបានចាត់តាំងឱ្យកាន់មុខតំណែងជា អ្នកគ្រប់គ្រងជំនាញដទៃទៀតជាច្រើន។ ក្នុងឆ្នាំ២០០៩ លោកត្រូវបានតែងតាំងជា នាយកការិយាល័យសិក្សា នៃនាយកដ្ឋានហ្វឹកហ្វឺន ធនាគារ អេស៊ីលីដា និងបន្ទាប់មកជានាយករងនាយកដ្ឋានហ្វឹកហ្វឺន ធនាគារ អេស៊ីលីដា នៅឆ្នាំ ២០១១ ។ នៅឆ្នាំ២០១២ លោកមានតំណែងជា នាយកនាយកដ្ឋានហ្វឹកហ្វឺន នៃ អេស៊ីលីដា ត្រេននីង សេនធ័រ ។ ឆ្នាំ២០១៣ លោកទទួលមុខតំណែងជា នាយកការិយាល័យសិក្សា និងចាប់ពីដើមឆ្នាំ២០១៤ មកដល់បច្ចុប្បន្ន លោកមានមុខតំណែងជា ទីប្រឹក្សា នៃ អេស៊ីលីដា ត្រេននីង សេនធ័រ ។

# ក្រមសីលធម៌

ក្នុងក្រមសីលធម៌របស់ក្រុមប្រឹក្សាភិបាល គ្រប់គ្រងដោយ ៖

១. អនុស្សរណៈ និងលក្ខន្តិកៈរបស់អេស៊ីលីដា ត្រេននីង សេនធ័រ

២. កិច្ចព្រមព្រៀងភាគទុនិក និង

៣. ច្បាប់ និងបទប្បញ្ញត្តិទាំងឡាយដែលពាក់ព័ន្ធរបស់ ព្រះរាជាណាចក្រកម្ពុជា

វិវឌ្ឍនាការតគលប់ឈររបស់ អេស៊ីលីដា ត្រេននីង សេនធ័រ គឺទាមទារឱ្យមានការយកចិត្តទុកដាក់ខ្ពស់ ដើម្បីធានាថា បទដ្ឋាននៃការអនុវត្តផ្ទៃក្នុងរបស់សាជីវកម្ម ត្រូវបានរក្សាក្នុងកម្រិតមួយខ្ពស់បំផុត ។ ក្នុងចំណោមបញ្ហាផ្សេងៗនោះ រួមមាន៖ កិច្ចព្រមព្រៀងលើការផ្តល់សេវារបស់ក្រុមប្រឹក្សាភិបាល កម្មវិធីបណ្តុះបណ្តាល តួនាទី មុខងាររបស់ក្រុមប្រឹក្សាភិបាល បញ្ជីវាយតម្លៃក្រុមប្រឹក្សាភិបាល និងក្រមសីលធម៌របស់ក្រុមប្រឹក្សាភិបាល ត្រូវបានរៀបចំដាក់ឱ្យប្រើប្រាស់ ហើយតួនាទីទាក់ទងទៅនឹងប្រាក់លាភការ និងការចំណាយរបស់ក្រុមប្រឹក្សាភិបាល ត្រូវបានរៀបចំជាទម្រង់យ៉ាងច្បាស់លាស់ ។

និយោជិតគ្រប់រូបរបស់ អេស៊ីលីដា ត្រេននីង សេនធ័រ ស្ថិតក្រោមការគ្រប់គ្រងមួយយ៉ាងតឹងរឹងនៃ ក្រមសីលធម៌ដែលបានកំណត់ក្នុងអនុសញ្ញារួមការងារ ដោយគ្របដណ្តប់លើបញ្ហាមួយចំនួនដូចជា៖ ចរិត លក្ខណបុគ្គល ទំនាក់ទំនងជាមួយអ្នករួមការងារ អតិថិជន និងអ្នកគ្រប់គ្រង អាថ៌កំបាំងវិជ្ជាជីវៈ វិវាទលើផលប្រយោជន៍ ការទទួលយកអំណោយ ការសម្អាតប្រាក់ និងការបោកអាក្រាតកំហុសឆ្គង ។

ឯកសារទាំងនេះ ត្រូវបានត្រួតពិនិត្យសារឡើងវិញយ៉ាងទៀងទាត់ដោយសវនករ ដើម្បីធានាថា វានៅតែ មានសុពលភាពប្រើប្រាស់ និងទាន់សម័យ ។



ក្រុមប្រឹក្សាភិបាល អេស៊ីលីដា ត្រេននីង សេនធ័រ រំលឹកគុណមាតា-បិតា មុនបើកកិច្ចប្រជុំ



លោកអគ្គនាយក អេស៊ីលីដា ត្រេននីង សេនធ័រ និងសិក្ខាកាម រំលឹកគុណមាតា-បិតា មុនពិធីបើកវគ្គហ្វឹកហ្វឺន

# របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សវនករឯករាជ

សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤

## មាតិកា


របាយការណ៍ក្រុមប្រឹក្សាភិបាល..........២៤

របាយការណ៍សវនករឯករាជ ..........២៦

របាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ..........២៧

របាយការណ៍លទ្ធផលលម្អិត..........២៨

របាយការណ៍បម្រែបម្រួលមូលធន ..........២៩

របាយការណ៍លំហូរសាច់ប្រាក់..........៣០

កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ..........៣១




សមាសភាពគណៈកម្មាធិការប្រតិបត្តិ អេស៊ីលីដា ព្រែននីង សេនធ័រ

# របាយការណ៍ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល មានសេចក្តីសោមនស្សក្នុងការដាក់បង្ហាញរបាយការណ៍របស់ខ្លួន និងរបាយការណ៍ហិរញ្ញវត្ថុ ដែលបានធ្វើសវនកម្មរួចរបស់ក្រុមហ៊ុន អេស៊ីលីដា ត្រេននីង សេនធ័រ លីមីតធីត (ហៅកាត់ថា "ក្រុមហ៊ុន") សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤។

## អំពីក្រុមហ៊ុន

ក្រុមហ៊ុន គឺជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ដែលត្រូវបានបង្កើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា សម្រាប់រយៈពេល៩៩ឆ្នាំ ដែលបានចុះបញ្ជីលេខ Co.1332KH/2011 ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១១ ពីក្រសួងពាណិជ្ជកម្ម ។ ក្រុមហ៊ុនត្រូវបានកាន់កាប់ទាំងស្រុងដោយ ធនាគារ អេស៊ីលីដា ភីអិលស៊ី ។

## សកម្មភាពចម្បង

សកម្មភាពចម្បងរបស់ក្រុមហ៊ុន គឺផ្តល់នូវសេវាកម្មបណ្តុះបណ្តាលជំនាញធុរកិច្ចធនាគារ និងហិរញ្ញវត្ថុ ប្រកបដោយគុណភាពខ្ពស់បំផុត ទៅដល់សិក្ខាកាមដែលចូលរួមទាំងក្នុងស្រុក និងអន្តរជាតិ ព្រមទាំងសកម្មភាពផ្សេងៗទៀត ដែលស្របតាមកម្មវត្ថុ នៃមុខជំនាញនេះ តាមរយៈសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុសម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍លទ្ធផលលម្អិត នៅលើទំព័រទី២៧។

មិនមានភាគលាភត្រូវបានបែងចែក ឬបានបង់ទៅឱ្យសមាជិក ក្នុងអំឡុងដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ នោះទេ (ឆ្នាំ២០១៣ ៖ គ្មាន)។

## ទ្រព្យសកម្ម

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលអាចបណ្តាលឱ្យតម្លៃទ្រព្យសកម្មក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនពុំត្រឹមត្រូវជាសារវន្តទេ។

## វិធីសាស្ត្រវាយតម្លៃ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាលៈទេសៈណាមួយដែលបានកើតឡើង ហើយអាចបណ្តាលឱ្យប៉ះពាល់ដល់វិធីសាស្ត្រវាយតម្លៃទ្រព្យសកម្ម និងបំណុលដែលមានស្រាប់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មានភាពមិនត្រឹមត្រូវ ឬមិនសមស្របជាសារវន្តនោះទេ។

## បំណុលយថាភាព និងបំណុលផ្សេងៗ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះមិនមាន ៖

ក. បន្ទុកណាមួយលើទ្រព្យសកម្មរបស់ក្រុមហ៊ុន ដែលបានកើតឡើងដោយសារការដាក់វាបញ្ចាំ សម្រាប់ការធានាបំណុលរបស់បុគ្គលណាម្នាក់ឡើយ ចាប់តាំងពីដំណាច់ឆ្នាំមក និង

ខ. បំណុលយថាភាពណាមួយរបស់ក្រុមហ៊ុន ដែលបានកើតឡើងចាប់តាំងពីដំណាច់ឆ្នាំមក

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល ពុំមានបំណុលយថាភាព ឬបំណុលផ្សេងៗរបស់ក្រុមហ៊ុន បានក្លាយជា ការបង្ខំឱ្យសង ឬអាចនឹងត្រូវទាមទារឱ្យសងក្នុងរយៈពេល១២ខែបន្ទាប់ពីដំណាច់ឆ្នាំ ដែលនឹង ឬអាចនឹងមានផលប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន នៅថ្ងៃដល់ពេលកំណត់សងនោះទេ។

## ការប្រែប្រួលកាលៈទេសៈ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលមិនបានដឹងពីកាលៈទេសៈណាមួយដែលមិនបានវែកញែកនៅក្នុងរបាយការណ៍នេះ ឬរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដែលអាចបណ្តាលឱ្យចំនួនទឹកប្រាក់ដែលបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុ មានភាពមិនត្រឹមត្រូវជាសារវន្តនោះទេ។

## ប្រតិបត្តិការមិនប្រក្រតី

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ មិនបានទទួលរងនូវផលប៉ះពាល់ជាសារវន្តពីខ្វង់គណនីប្រតិបត្តិការ ឬព្រឹត្តិការណ៍មិនប្រក្រតីណាមួយឡើយ។

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល នៅចន្លោះពេលរវាងដំណាច់ឆ្នាំនេះរហូតមកទល់នឹងកាលបរិច្ឆេទនៃរបាយការណ៍មិនមានខ្វង់គណនី ប្រតិបត្តិការ ឬព្រឹត្តិការណ៍ខុសប្រក្រតីណាមួយ ដែលអាចជះឥទ្ធិពលជាសារវន្ត ដល់លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុននៅក្នុងឆ្នាំនោះទេ។

## ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនក្នុងអំឡុងឆ្នាំ និងរហូតដល់កាលបរិច្ឆេទនៃរបាយការណ៍នេះ មានរាយនាមដូចខាងក្រោម ៖

| | | |
|---|---|---|
| ១. | បណ្ឌិត សូ ផនណារី | ប្រធានក្រុមប្រឹក្សាភិបាល |
| ២. | លោក ព្រំ វិសុទ្ធ | សមាជិកក្រុមប្រឹក្សាភិបាល |
| ៣. | បណ្ឌិត អ៊ុង សំអុល | សមាជិកក្រុមប្រឹក្សាភិបាល |



សកម្មភាពវគ្គសិក្ខាសាលាបណ្តុះបណ្តាលជំនាញគ្រូហ្វឹកហ្វឺន ដែលបង្រៀនដោយសាស្ត្រាចារ្យមកពីសកលវិទ្យាល័យ Harvard

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល លើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវក្នុងការបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើង និងបានបង្ហាញត្រឹមត្រូវ នូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ នៃស្ថានភាពហិរញ្ញវត្ថុ របស់ក្រុមហ៊ុន គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់ក្រុមហ៊ុន សម្រាប់ដំណាច់ឆ្នាំ ។ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ក្រុមប្រឹក្សាភិបាលត្រូវ ៖

១. អនុវត្តគោលការណ៍គណនេយ្យសមស្រប ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម (ហៅកាត់ថា "CIFRS for SMEs") ដែលគាំទ្រដោយការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រកបដោយការប្រុងប្រយ័ត្ន ព្រមទាំងអនុវត្តតាមគោលការណ៍ទាំងនេះ ឱ្យមានសង្គតិភាព ។

២. អនុវត្តតាមតម្រូវការក្នុងការលាតត្រដាងព័ត៌មាន របស់ CIFRS for SMEs ហើយប្រសិនបើមានការប្រាសចាកណាមួយ ក្នុងការបង្ហាញឱ្យមានភាពត្រឹមត្រូវ និងសមរម្យ ក្រុមប្រឹក្សាភិបាលត្រូវប្រាកដថាការប្រាសចាកទាំងនោះ ត្រូវបានបង្ហាញពន្យល់ និងកំណត់បរិមាណឱ្យបានត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

៣. រក្សាទុកកំណត់ត្រាគណនេយ្យឱ្យបានគ្រប់គ្រាន់ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាព ។

៤. រៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដោយផ្អែកលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម លើកលែងតែមានករណីសន្មតយ៉ាងសមរម្យថា ក្រុមហ៊ុននឹងមិនអាចបន្តកិច្ចប្រតិបត្តិការអាជីវកម្មនៅពេលអនាគតដ៏ខ្លី និង

៥. គ្រប់គ្រង និងដឹកនាំក្រុមហ៊ុនឱ្យមានប្រសិទ្ធភាព តាមរយៈការសម្រេចចិត្តជាសារវន្តទាំងអស់ ដែលជះឥទ្ធិពលដល់ប្រតិបត្តិការ និងលទ្ធផលរបស់ក្រុមហ៊ុន ហើយត្រូវធានាថា ផលប៉ះពាល់ទាំងនោះត្រូវបានឆ្លុះបញ្ចាំងត្រឹមត្រូវ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

ក្រុមប្រឹក្សាភិបាលធានាអះអាងថា ក្រុមហ៊ុនបានអនុវត្តតាមតម្រូវការខាងលើ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ។

## របាយការណ៍ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលសូមធានាអះអាងថា របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានបង្ហាញត្រឹមត្រូវ នូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ នៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ និងលទ្ធផលអាជីវកម្ម បម្រែបម្រួលមូលធន ព្រមទាំងលំហូរសាច់ប្រាក់របស់ក្រុមហ៊ុន សម្រាប់ដំណាច់ឆ្នាំហិរញ្ញវត្ថុ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម ។

តាងនាមឱ្យក្រុមប្រឹក្សាភិបាល

បណ្ឌិត សូ ផនណារី
ប្រធានក្រុមប្រឹក្សាភិបាល
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
កាលបរិច្ឆេទ៖ ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៥



បណ្ឌិត សូ ផនណារី ប្រធានក្រុមប្រឹក្សាភិបាល ធ្វើបទបង្ហាញជូនដល់សិក្ខាកាម ដែលជាប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ នៃប្រទេសស្រីលង្កា

# របាយការណ៍សវនករឯករាជ

## ជូនភាគទុនិកក្រុមហ៊ុន អេស៊ីលីដា ត្រេននីង សេនធ័រ លីមីតធីត

យើងខ្ញុំបានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន អេស៊ីលីដា ត្រេននីង សេនធ័រ លីមីតធីត (ហៅកាត់ថា "ក្រុមហ៊ុន") រួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ និងរបាយការណ៍លទ្ធផលលម្អិត របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ រួមទាំងកំណត់សម្គាល់នានា ព្រមទាំងសេចក្ដីសង្ខេបនៃគោលការណ៍គណនេយ្យសំខាន់ៗ និងព័ត៌មានពន្យល់ដទៃទៀត ។

## ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រងលើរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រងទទួលខុសត្រូវក្នុងការរៀបចំ និងការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុទាំងនេះឱ្យបានត្រឹមត្រូវ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម និងទទួលខុសត្រូវលើការត្រួតពិនិត្យផ្ទៃក្នុង ដែលគណៈគ្រប់គ្រងកំណត់ថាវាមានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ មិនឱ្យមានការរាយការណ៍ខុសជាសារវន្ត ដែលបណ្ដាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ ។

## ការទទួលខុសត្រូវរបស់សវនករ

ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺបញ្ចេញមតិលើរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ដោយផ្អែកទៅលើ ការធ្វើសវនកម្មរបស់យើងខ្ញុំ។ យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារអន្តរជាតិស្តីពីសវនកម្មនៃកម្ពុជា។ ស្តង់ដារទាំងនោះ តម្រូវឱ្យយើងខ្ញុំប្រតិបត្តិតាមក្រមសីលធម៌ ធ្វើផែនការ និងធ្វើសវនកម្ម ដើម្បីទទួលបាននូវការធានាអះអាងដែលសមហេតុផលថា របាយការណ៍ហិរញ្ញវត្ថុពុំមានលក្ខណៈខុសឆ្គងជាសារវន្ត។

ការធ្វើសវនកម្មរួមមាន៖ ការអនុវត្តនីតិវិធី ដើម្បីទទួលបាននូវភស្តុតាងសវនកម្ម អំពីចំនួនទឹកប្រាក់ និងការលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។ ការជ្រើសរើសនីតិវិធីទាំងនេះ គឺអាស្រ័យលើការវិនិច្ឆ័យរបស់សវនករ រាប់ទាំងការវាយតម្លៃលើហានិភ័យ នៃភាពខុសឆ្គងជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុ ដែលបណ្ដាលមកពីការក្លែងបន្លំ ឬកំហុសឆ្គង ។ ក្នុងការវាយតម្លៃហានិភ័យទាំងនោះ សវនករបានពិចារណាទៅលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់អង្គភាពដែលទាក់ទងទៅនឹងការរៀបចំ និងការបង្ហាញយ៉ាងត្រឹមត្រូវ នៃរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីរៀបចំនូវនីតិវិធីសវនកម្ម ដែលមានលក្ខណៈសមហេតុផលទៅតាមកាលៈទេសៈផ្សេងៗ ប៉ុន្តែពុំមានគោលបំណងបញ្ចេញមតិទៅលើប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់អង្គភាពនោះទេ ។ សវនកម្មក៏រួមបញ្ចូលទាំងការវាយតម្លៃនូវភាពសមស្របនៃគោលការណ៍គណនេយ្យដែលបានប្រើប្រាស់ និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យ ដែលធ្វើឡើងដោយគណៈគ្រប់គ្រង ក៏ដូចជាការវាយតម្លៃលើការបង្ហាញជាទូទៅនៃរបាយការណ៍ហិរញ្ញវត្ថុ ។

យើងខ្ញុំជឿជាក់ថាភស្តុតាងសវនកម្មដែលយើងទទួលបាន គឺមានលក្ខណៈគ្រប់គ្រាន់ និងត្រឹមត្រូវ ដែលជាមូលដ្ឋានសម្រាប់ការបញ្ចេញមតិយោបល់របស់យើងខ្ញុំ ។

## មតិយោបល់

តាមទស្សនៈរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុ បានបង្ហាញត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ នៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន អេស៊ីលីដា ត្រេននីង សេនធ័រ លីមីតធីត គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម ។

ជំ. PricewaterhouseCoopers ( Cambodia ) Ltd.




គុយ លីម
នាយក

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
កាលបរិច្ឆេទ៖ ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៥



កម្មករនិយោជិតរបស់ អេស៊ីលីដា មីក្រូហិរញ្ញវត្ថុ មីយ៉ាន់ម៉ា ចូលរួមវគ្គហ្វឹកហាត់ការងារ នៅព្រះរាជាណាចក្រកម្ពុជា

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤

| | កំណត់សម្គាល់ | ២០១៤ | | ២០១៣ | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ទ្រព្យសកម្ម** | | | | | |
| ទ្រព្យសកម្មរយៈពេលខ្លី | | | | | |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | ៥ | ៨៣៧.១៩១ | ៣.៤១១.៥៥៣ | ២.៧៨៥.៨០៥ | ១១.១២៩.២៩១ |
| ប្រាក់បញ្ញើមានកាលកំណត់ | ៦ | ២.៦៧១.២០៩ | ១០.៨៨៥.១៧៧ | - | - |
| ប្រាក់ជំនួយត្រូវទទួល | | ១៣៧.៤៤៧ | ៥៦០.០៩៦ | ១០.៧៨៤ | ៤៣.០៨២ |
| គណនីត្រូវទទួលផ្សេងៗ | ៧ | ២៦៤.៤៣៩ | ១.០៧៧.៥៨៩ | ១១.៧៧៧ | ៤៧.០៤៩ |
| | | ៣.៩១០.២៨៦ | ១៥.៩៣៤.៤១៥ | ២.៨០៨.៣៦៦ | ១១.២១៩.៤២២ |
| ទ្រព្យសកម្មរយៈពេលវែង | | | | | |
| ទ្រព្យសម្បត្តិ និងបរិក្ខារ | ៨ | ១២.៤៨០.២៥១ | ៥០.៨៥៧.០២៣ | ១៦៣.៧៣៧ | ៦៥៤.១២៩ |
| ទ្រព្យសកម្មអរូបី | ៩ | ១.០០៧ | ៤.១០៤ | ១.២៩២ | ៥.១៦២ |
| ពន្ធពន្យារទ្រព្យសកម្ម | ១០ | ៩១.៤៨០ | ៣៧២.៧៨១ | ៧៦.៣៥៩ | ៣០៥.០៥៤ |
| ការវិនិយោគផ្សេងៗ | ១១ | ៣៧.២៩២ | ១៥១.៩៦៥ | - | - |
| | | ១២.៦១០.០៣០ | ៥១.៣៨៥.៨៧៣ | ២៤១.៣៨៨ | ៩៦៤.៣៤៥ |
| ទ្រព្យសកម្មសរុប | | ១៦.៥២០.៣១៦ | ៦៧.៣២០.២៨៨ | ៣.០៤៩.៧៥៤ | ១២.១៨៣.៧៦៧ |
| **បំណុល និងមូលធន** | | | | | |
| **បំណុល** | | | | | |
| បំណុលរយៈពេលខ្លី | | | | | |
| បង្គរ និងគណនីត្រូវទូទាត់ផ្សេងៗ | ១២ | ៣៤៤.៨១៥ | ១.៤០៥.១២២ | ២៦៩.៦៥៥ | ១.០៧៧.២៧២ |
| បំណុលពន្ធលើប្រាក់ចំណេញ | ១៩(ក) | ២០៤.៩២៥ | ៨៣៥.០៦៩ | ២៧៣.៦៦៨ | ១.០៩៣.៣០៤ |
| | | ៥៤៩.៧៤០ | ២.២៤០.១៩១ | ៥៤៣.៣២៣ | ២.១៧០.៥៧៦ |
| បំណុលរយៈពេលវែង | | | | | |
| សំវិធានធនសម្រាប់អត្ថប្រយោជន៍បុគ្គលិក | ១៣ | ១៩១.១៩០ | ៧៧៩.០៩៩ | ១៩៨.៦៦៥ | ៧៩៣.៦៦៧ |
| បំណុលសរុប | | ៧៤០.៩៣០ | ៣.០១៩.២៩០ | ៧៤១.៩៨៨ | ២.៩៦៤.២៤៣ |
| **មូលធន** | | | | | |
| ដើមទុន | ១៤ | ១២.៨០៥.០០០ | ៥២.១៨០.៣៧៥ | ២០៥.០០០ | ៨១៨.៩៧៥ |
| ចំណេញរក្សាទុក | | ២.៩៧៤.៣៨៦ | ១១.៩៩១.៦៥៨ | ២.១០២.៧៦៦ | ៨.៤៧២.០៥៧ |
| ទុនបម្រុងផ្សេងៗ | | - | ១២៨.៩៦៥ | - | (៧១.៥០៨) |
| មូលធនសរុប | | ១៥.៧៧៩.៣៨៦ | ៦៤.៣០០.៩៩៨ | ២.៣០៧.៧៦៦ | ៩.២១៩.៥២៤ |
| បំណុល និងមូលធនសរុប | | ១៦.៥២០.៣១៦ | ៦៧.៣២០.២៨៨ | ៣.០៤៩.៧៥៤ | ១២.១៨៣.៧៦៧ |

# របាយការណ៍លទ្ធផលលម្អិត

សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤

| | កំណត់សម្គាល់ | ២០១៤ | | ២០១៣ | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ចំណូល | ១៥ | ៣.៣២៨.៣១៤ | ១៣.៤៣៩.៧៣២ | ៣.៥០៤.៧០២ | ១៤.១១៣.៤៣៥ |
| ថ្លៃដើមនៃសេវាកម្ម | ១៦ | (១.០៦៥.៨២៩) | (៤.៣០៣.៨១៨) | (៨៨៤.៥៦៥) | (៣.៥៦២.១៤៣) |
| ចំណេញដុល | | ២.២៦២.៤៨៥ | ៩.១៣៥.៩១៤ | ២.៦២០.១៣៧ | ១០.៥៥១.២៩២ |
| ចំណាយរដ្ឋបាល | ១៧ | (១.៣៨២.២១៣) | (៥.៥៨១.៣៧៦) | (១.១៤៨.២២០) | (៤.៦២៣.៨៨២) |
| ចំណូលផ្សេងៗ | | ៨៩៩ | ៣.៦៣០ | ២.២៤០ | ៩.០២០ |
| (ខាត)/ចំណេញផ្សេងៗ- សុទ្ធ | | (១.៦៨៣) | (៦.៧៩៦) | ៥.៣០៣ | ២១.៣៥៥ |
| ចំណេញពីប្រតិបត្តិការ | | ៨៧៩.៤៨៨ | ៣.៥៥១.៣៧២ | ១.៤៧៩.៤៦០ | ៥.៩៥៧.៧៨៥ |
| ចំណូលពីប្រាក់ជំនួយ | ១៨ | ៦៦.៦៩០ | ២៦៩.២៩៤ | ១០៤.៩៨៨ | ៤២២.៧៨៧ |
| ចំណូលការប្រាក់ | | ១៤៧.៦៦៦ | ៥៩៦.២៧៥ | - | - |
| ចំណេញមុនបង់ពន្ធលើប្រាក់ចំណេញ | | ១.០៩៣.៨៤៤ | ៤.៤១៦.៩៤១ | ១.៥៨៤.៤៤៨ | ៦.៣៨០.៥៧២ |
| ចំណាយពន្ធលើប្រាក់ចំណេញ | ១៩(ខ) | (២២២.២២៤) | (៨៩៧.៣៤០) | (៣១៦.៤២៦) | (១.២៧៤.២៤៨) |
| ចំណេញសម្រាប់ដំណាច់ឆ្នាំ | | ៨៧១.៦២០ | ៣.៥១៩.៦០១ | ១.២៦៨.០២២ | ៥.១០៦.៣២៤ |
| ចំណូលលម្អិតផ្សេងៗ | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | ២០០.៤៧៣ | - | (៤០.៥៧៧) |
| សរុបលទ្ធផលលម្អិតសម្រាប់ដំណាច់ឆ្នាំ | | ៨៧១.៦២០ | ៣.៧២០.០៧៤ | ១.២៦៨.០២២ | ៥.០៦៥.៧៤៧ |
| ចំណេញបែងចែកទៅឱ្យ | | | | | |
| ម្ចាស់ក្រុមហ៊ុន | | ៨៧១.៦២០ | ៣.៥១៩.៦០១ | ១.២៦៨.០២២ | ៥.១០៦.៣២៤ |
| សរុបចំណូលលម្អិតបែងចែកទៅឱ្យ | | | | | |
| ម្ចាស់ក្រុមហ៊ុន | | ៨៧១.៦២០ | ៣.៧២០.០៧៤ | ១.២៦៨.០២២ | ៥.០៦៥.៧៤៧ |



កិច្ចប្រជុំមប្រចាំឆ្នាំរវាងថ្នាក់ដឹកនាំ និងកម្មករនិយោជិត អេស៊ីលីដា គ្រេននីង សេនធ័រ

# របាយការណ៍បម្រែបម្រួលមូលធន

សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤

| | ដើមទុន | | ចំណេញរក្សាទុក | | ទុនបម្រុងផ្សេងៗ | សរុប | |
|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣** | | | | | | | |
| សមតុល្យគិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០១៣ | ២០៥.០០០ | ៨១៨.៩៧៥ | ៨៣៤.៧៤៤ | ៣.៣៦៥.៧៣៣ | (៣០.៩៣១) | ១.០៣៩.៧៤៤ | ៤.១៥៣.៧៧៧ |
| ចំណូលលម្អិត: | | | | | | | |
| ចំណេញក្នុងឆ្នាំ | - | - | ១.២៦៨.០២២ | ៥.១០៦.៣២៤ | - | ១.២៦៨.០២២ | ៥.១០៦.៣២៤ |
| ចំណូលលម្អិតផ្សេងៗ- លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | (៤០.៥៧៧) | - | (៤០.៥៧៧) |
| សរុបចំណូលលម្អិតក្នុងឆ្នាំ | - | - | ១.២៦៨.០២២ | ៥.១០៦.៣២៤ | (៤០.៥៧៧) | ១.២៦៨.០២២ | ៥.០៦៥.៧៤៧ |
| ប្រតិបត្តិការជាមួយម្ចាស់ក្រុមហ៊ុន: | | | | | | | |
| *ដើមទុនបន្ថែមបានបង់ (កំណត់សម្គាល់ ១៤)* | - | - | - | - | - | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - |
| **សមតុល្យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣** | ២០៥.០០០ | ៨១៨.៩៧៥ | ២.១០២.៧៦៦ | ៨.៤៧២.០៥៧ | (៧១.៥០៨) | ២.៣០៧.៧៦៦ | ៩.២១៩.៥២៤ |
| **សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤** | | | | | | | |
| សមតុល្យគិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០១៤ | ២០៥.០០០ | ៨១៨.៩៧៥ | ២.១០២.៧៦៦ | ៨.៤៧២.០៥៧ | (៧១.៥០៨) | ២.៣០៧.៧៦៦ | ៩.២១៩.៥២៤ |
| ចំណូលលម្អិត: | | | | | | | |
| ចំណេញក្នុងឆ្នាំ | - | - | ៨៧១.៦២០ | ៣.៥១៩.៦០១ | - | ៨៧១.៦២០ | ៣.៥១៩.៦០១ |
| ចំណូលលម្អិតផ្សេងៗ- លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | ២០០.៤៧៣ | - | ២០០.៤៧៣ |
| សរុបចំណូលលម្អិតក្នុងឆ្នាំ | - | - | ៨៧១.៦២០ | ៣.៥១៩.៦០១ | ២០០.៤៧៣ | ៨៧១.៦២០ | ៣.៧២០.០៧៤ |
| ប្រតិបត្តិការជាមួយម្ចាស់ក្រុមហ៊ុន: | | | | | | | |
| ដើមទុនបន្ថែមបានបង់ (កំណត់សម្គាល់ ១៤) | ១២.៦០០.០០០ | ៥០.៨០៣.២០០ | - | - | - | ១២.៦០០.០០០ | ៥០.៨០៣.២០០ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | ៥៥៨.២០០ | - | - | - | - | ៥៥៨.២០០ |
| ***សមតុល្យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤*** | ១២.៨០៥.០០០ | ៥២.១៨០.៣៧៥ | ២.៩៧៤.៣៨៦ | ១១.៩៩១.៦៥៨ | ១២៨.៩៦៥ | ១៥.៧៧៩.៣៨៦ | ៦៤.៣០០.៩៩៨ |

# របាយការណ៍លំហូរសាច់ប្រាក់

សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤

| | កំណត់សម្គាល់ | ២០១៤ | | ២០១៣ | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | | |
| ចំណេញមុនបង់ពន្ធលើប្រាក់ចំណេញ | | ១.០៩៣.៨៤៤ | ៤.៤១៦.៩៤១ | ១.៥៨៤.៤៤៨ | ៦.៣៨០.៥៧២ |
| *និយ័តកម្មសម្រាប់:* | | | | | |
| រំលស់ទ្រព្យរូបី | ៨ | ៧២.៩៣៣ | ២៩៤.៥០៣ | ៤៤.៣៨៤ | ១៧៨.៧៣៤ |
| រំលស់ទ្រព្យអរូបី | ៩ | ២៨៥ | ១.១៥១ | ១៣៥ | ៥៤៤ |
| ខាត/(ចំណេញ)ពីការលក់ចេញទ្រព្យសម្បត្តិ និង បរិក្ខារ | | ៦៥៩ | ២.៦៦១ | (៦០៧) | (២.៤៤៤) |
| | | ១.១៦៧.៧២១ | ៤.៧១៥.២៥៦ | ១.៦២៨.៣៦០ | ៦.៥៥៧.៤០៦ |
| **បម្រែបម្រួលក្នុងដើមទុនបង្វិល:** | | | | | |
| ប្រាក់ជំនួយត្រូវទទួល | | (១២៦.៦៦៣) | (៥១១.៤៦៥) | (១០.៧៨៤) | (៤៣.៤២៧) |
| គណនីត្រូវទទួលផ្សេងៗ | | (២៥២.៦៦២) | (១.០២០.២៤៩) | ៨៩.១៨៥ | ៣៥៩.១៤៨ |
| បង្គរ និងគណនីត្រូវទូទាត់ផ្សេងៗ | | ៧៥.១៦០ | ៣០៣.៤៩៦ | (២៧.៧៣៣) | (១១១.៦៨១) |
| អត្ថប្រយោជន៍ពេលចូលនិវត្តន៍ | | (៧.៤៧៥) | (៣០.១៨៤) | (២៣.៤០៣) | (៩៤.២៤៤) |
| សាច់ប្រាក់បានពីប្រតិបត្តិការ | | ៨៥៦.០៨១ | ៣.៤៥៦.៨៥៤ | ១.៦៥៥.៦២៥ | ៦.៦៦៧.២០២ |
| ពន្ធលើប្រាក់ចំណេញបានបង់ | ១៩(ក) | (៣០៦.០៨៨) | (១.២៣៥.៩៨៣) | (២៤០.៩២២) | (៩៧០.១៩៣) |
| សាច់ប្រាក់សុទ្ធបានពីសកម្មភាពប្រតិបត្តិការ | | ៥៤៩.៩៩៣ | ២.២២០.៨៧១ | ១.៤១៤.៧០៣ | ៥.៦៩៧.០០៩ |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| ការទិញទ្រព្យសម្បត្តិ និងបរិក្ខារ | ៨ | (១២.៣៩០.១០៦) | (៥០.០៣១.២៤៨) | (១២០.៩១១) | (៤៨៦.៩០៩) |
| ការទិញទ្រព្យសកម្មអរូបី | ៩ | - | - | (១.៤២៧) | (៥.៧៤៧) |
| សាច់ប្រាក់បានពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ | | - | - | ៦៩០ | ២.៧៧៩ |
| ប្រាក់បញ្ញើមានកាលកំណត់ | | (២.៦៧១.២០៩) | (១០.៧៨៦.៣៤២) | - | - |
| ការវិនិយោគផ្សេងៗ | ១១ | (៣៧.២៩២) | (១៥០.៥៨៥) | - | - |
| សាច់ប្រាក់សុទ្ធបានប្រើក្នុងសកម្មភាពវិនិយោគ | | (១៥.០៩៨.៦០៧) | (៦០.៩៦៨.១៧៥) | (១២១.៦៤៨) | (៤៨៩.៨៧៧) |
| **លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | | |
| សាច់ប្រាក់បានពីដើមទុនបន្ថែមបានបង់ | ១៤ | ១២.៦០០.០០០ | ៥០.៨០៣.២០០ | - | - |
| សាច់ប្រាក់សុទ្ធបានពីសកម្មភាពហិរញ្ញប្បទាន | | ១២.៦០០.០០០ | ៥០.៨០៣.២០០ | - | - |
| (តំហយ)/កំណើនសុទ្ធនៃសាច់ប្រាក់ និង សាច់ប្រាក់សមមូល | | (១.៩៤៨.៦១៤) | (៧.៩៤៤.១០៤) | ១.២៩៣.០៥៥ | ៥.២០៧.១៣២ |
| សាច់ប្រាក់និងសាច់ប្រាក់សមមូលដើមឆ្នាំ | | ២.៧៨៥.៨០៥ | ១១.១២៩.២៩១ | ១.៤៩២.៧៥០ | ៥.៩៦៣.៥៣៦ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | ២២៦.៣៦៦ | - | (៤១.៣៧៧) |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលចុងឆ្នាំ** | ៥ | ៨៣៧.១៩១ | ៣.៤១១.៥៥៣ | ២.៧៨៥.៨០៥ | ១១.១២៩.២៩១ |



គណៈប្រតិភូធនាគារជាតិឡាវធ្វើទស្សនកិច្ចនៅព្រះបរមរាជវាំង ក្នុងឱកាសចូលរួមវគ្គសិក្ខាសាលា និងទស្សនកិច្ចផ្លាស់ប្តូរបទពិសោធន៍ នៅព្រះរាជាណាចក្រកម្ពុជា

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ

សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤

## ១. ព័ត៌មានទូទៅ

ក្រុមហ៊ុនអេស៊ីលីដា ត្រេននីង សេនធ័រ លីមីតធីត ហៅកាត់ថា("ក្រុមហ៊ុន") ត្រូវបានបង្កើតឡើងជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតដែលត្រូវបានបង្កើតឡើងនៅក្នុងព្រះរាជាណាចក្រសម្រាប់រយៈពេល៩៩ឆ្នាំ ដែលចុះបញ្ជីលេខ Co.1332KH/2011 ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១១ ពីក្រសួងពាណិជ្ជកម្ម។ ក្រុមហ៊ុនបានចាប់ផ្តើមប្រតិបត្តិការរបស់ខ្លួន នៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១១។ ក្រុមហ៊ុនត្រូវបានកាន់កាប់ទាំងស្រុងដោយធនាគារ អេស៊ីលីដា ភីអិលស៊ី។

សកម្មភាពចម្បងរបស់ក្រុមហ៊ុន គឺផ្តល់នូវសេវាកម្មបណ្តុះបណ្តាលចំណេះជំនាញធុរកិច្ចធនាគារ និងហិរញ្ញវត្ថុ ប្រកបដោយគុណភាពខ្ពស់បំផុតទៅដល់សិក្ខាកាមដែលចូលរួមទាំងក្នុងស្រុក និងអន្តរជាតិ ព្រមទាំងសកម្មភាពផ្សេងៗទៀត ដែលស្របតាមកម្មវត្ថុនៃមុខជំនាញនេះ តាមរយៈសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល។

ទីស្នាក់ការចុះបញ្ជីមានទីតាំងនៅអគារលេខ 50 ផ្លូវលេខ 516 កែង 335 ភូមិ 6 សង្កាត់បឹងកក់ 1 ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៤ ក្រុមហ៊ុនបានកត់ត្រាការទិញដីដែលមានទឹកប្រាក់ចំនួន ១២.២១៣.៩៣៦ ដុល្លារអាមេរិក។ ចំណាយនេះគឺបានមកពីដើមទុនរបស់ក្រុមហ៊ុនមេ។

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ក្រុមហ៊ុនមានបុគ្គលិកចំនួន ៩៣នាក់ (ឆ្នាំ២០១៣៖ ៧៩នាក់)។

ក្រុមប្រឹក្សាភិបាល បានអនុម័តឱ្យចេញផ្សាយរបាយការណ៍ហិរញ្ញវត្ថុនេះ នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៥។

## ២. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ

គោលការណ៍គណនេយ្យសំខាន់ៗ ដែលបានប្រើប្រាស់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានបង្ហាញដូចខាងក្រោម។ គោលការណ៍គណនេយ្យទាំងនេះត្រូវបានអនុវត្តយ៉ាងមានសង្គតិភាពគ្រប់ឆ្នាំទាំងអស់ដែលបានបង្ហាញ លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ។

### ២.១ មូលដ្ឋាននៃការរៀបចំ

របាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានរៀបចំឡើង ស្របតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុ អន្តរជាតិនៃកម្ពុជាសម្រាប់ សហគ្រាសធុនតូច និងមធ្យម។ របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើងតាមវិធីសាស្រ្តសន្មតថ្លៃដើម។

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដែលអនុលោមតាម CIFRS for SMEs តម្រូវឱ្យប្រើប្រាស់ការប៉ាន់ស្មានគណនេយ្យសំខាន់ៗ និងជាក់លាក់ ហើយក៏តម្រូវឱ្យគណៈគ្រប់គ្រងអនុវត្តការវិនិច្ឆ័យរបស់ខ្លួន នៅក្នុងដំណើរការនៃការអនុវត្តគោលការណ៍គណនេយ្យរបស់ក្រុមហ៊ុនផងដែរ ។ ផ្នែកដែលទាក់ទងនឹងកម្រិតខ្ពស់បំផុតនៃការវិនិច្ឆ័យ ឬភាពស្មុគស្មាញ ឬផ្នែកដែលការសន្មត ឬការប៉ាន់ស្មានមានលក្ខណៈជាសារវន្តចំពោះរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានលាតត្រដាងនៅក្នុងកំណត់សម្គាល់៣ ។

### ២.២ ការប្តូររូបិយប័ណ្ណបរទេស

*(ក) រូបិយប័ណ្ណគោល និងរូបិយប័ណ្ណសម្រាប់បង្ហាញ*

គណនីទាំងអស់ ដែលមាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានវាស់តម្លៃដោយប្រើប្រាស់រូបិយប័ណ្ណ នៃបរិយាកាសសេដ្ឋកិច្ចចម្បង ដែលក្រុមហ៊ុនធ្វើប្រតិបត្តិការ(ហៅកាត់ថា "រូបិយប័ណ្ណគោល") ។ ក្រុមហ៊ុនថែរក្សាកំណត់ត្រាគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន ជាប្រាក់ដុល្លារអាមេរិក ដែលជារូបិយប័ណ្ណគោល ។ របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក ដែលជារូបិយប័ណ្ណគោល និងរូបិយប័ណ្ណសម្រាប់បង្ហាញរបស់ក្រុមហ៊ុន ។

*(ខ) ប្រតិបត្តិការ និងសមតុល្យ*

ប្រតិបត្តិការជារូបិយប័ណ្ណផ្សេងៗ ត្រូវបានកត់ត្រាប្តូរទៅជារូបិយប័ណ្ណគោលដោយប្រើអត្រាប្តូរប្រាក់នាកាលបរិច្ឆេទនៃប្រតិបត្តិការនោះ។ ចំណេញ និងខាតពីការប្តូររូបិយប័ណ្ណដែលបណ្តាលមកពីការទូទាត់ប្រតិបត្តិការបែបនេះ និងពីការប្តូរទ្រព្យសកម្ម និងបំណុលរូបិយវត្ថុនានា ដែលកំណត់ជារូបិយប័ណ្ណផ្សេងៗក្រៅពីប្រាក់ដុល្លារអាមេរិកតាមអត្រាប្តូរប្រាក់នាដំណាច់ឆ្នាំ ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផលលម្អិត។

ចំណេញ និងខាតពីការប្តូររូបិយប័ណ្ណ ដែលទាក់ទិននឹងគណនីប្រាក់កម្ចី និងសាច់ប្រាក់ និងសាច់ប្រាក់សមមូល ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍លទ្ធផលលម្អិត ក្នុងគណនី "ចំណូល និងចំណាយហិរញ្ញវត្ថុ" ។ រាល់ចំណេញ និងខាតពីការប្តូររូបិយប័ណ្ណផ្សេងៗ ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍លទ្ធផលលម្អិត ក្នុងគណនី "ចំណេញ/(ខាត) ផ្សេងៗ-សុទ្ធ" ។

### ២.៣ ការបង្ហាញជាប្រាក់រៀល

អនុលោមតាមច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០២ និងយោងតាមប្រកាសលេខ : ៦៤៣សហវ.ប្រក របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០៧ តម្រូវឱ្យមានការប្តូរតួលេខនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ពីប្រាក់ដុល្លារអាមេរិកទៅជាប្រាក់រៀល ។ របាយការណ៍លទ្ធផលលម្អិត និងរបាយការណ៍លំហូរសាច់ប្រាក់ ត្រូវប្តូរទៅជាប្រាក់រៀល ដោយប្រើអត្រាមធ្យមភាគប្រចាំឆ្នាំ ។ ទ្រព្យសកម្ម និងបំណុលក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនីមួយៗ ដែលបានបង្ហាញ ហើយនិងមូលធនភាគទុនិក ត្រូវបានប្តូរតាមអត្រានាថ្ងៃបិទបញ្ជី គិតត្រឹមកាលបរិច្ឆេទរបាយការណ៍ ។ រាល់លម្អៀងពីការប្តូររូបិយប័ណ្ណផ្សេងៗ ត្រូវបានកត់ត្រានៅក្នុងលទ្ធផលលម្អិតផ្សេងៗ ។

ក្រុមហ៊ុនបានប្រើអត្រាប្តូរប្រាក់ផ្លូវការ ដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា។ គិតត្រឹមកាលបរិច្ឆេទរាយការណ៍នេះ អត្រាមធ្យមភាគប្រចាំឆ្នាំគឺ ១ដុល្លារអាមេរិក ស្មើនឹង ៤.០៣៨រៀល (ឆ្នាំ២០១៣៖ ១ដុល្លារអាមេរិក ស្មើនឹង៤.០២៧រៀល) ហើយអត្រាថ្ងៃបិទបញ្ជី១ដុល្លារអាមេរិក ស្មើនឹង ៤.០៧៥រៀល (ឆ្នាំ២០១៣៖ ១ដុល្លារអាមេរិក ស្មើនឹង៣.៩៩៥រៀល)។

### ២.៤ សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សាច់ប្រាក់ និងសាច់ប្រាក់សមមូល រួមមាន សាច់ប្រាក់ក្នុងដៃ ប្រាក់បញ្ញើអាចដកបានតាមតម្រូវការ ប្រាក់បញ្ញើសន្សំ និងការវិនិយោគរយៈពេលខ្លីដែលមានលទ្ធភាពបង្វិលជាសាច់ប្រាក់បានលឿន និងមានកាលកំណត់ដើមរយៈពេលបីខែ ឬតិចជាងបីខែ ។

### ២.៥ គណនីត្រូវទទួលផ្សេងៗ

គណនីត្រូវទទួលផ្សេងៗ ត្រូវបានទទួលស្គាល់ជាលើកដំបូង តាមតម្លៃរបស់ប្រតិបត្តិការ ហើយត្រូវបានវាស់វែងជាបន្តបន្ទាប់ តាមថ្លៃដើមដករំលស់ដោយប្រើវិធីសាស្រ្តអត្រាការប្រាក់មានប្រសិទ្ធភាព ដកសំវិធានធនសម្រាប់

ការថយចុះតម្លៃ ។ សំវិធានធនសម្រាប់ការថយចុះតម្លៃ ត្រូវបានបង្កើតឡើង នៅពេលដែលមានភស្តុតាងជាក់ស្តែងថា ក្រុមហ៊ុនមិនមានលទ្ធភាពប្រមូលប្រាក់ ដែលនៅសល់ទៅតាមលក្ខខណ្ឌដើម ។

## ២.៦ ទ្រព្យសម្បត្តិ និងបរិក្ខារ

គណនីទ្រព្យសម្បត្តិ និងបរិក្ខារ ត្រូវបានកត់ត្រា តាមថ្លៃដើមដករំលស់បង្គរ និងការខាតបង្គរដែលបណ្តាលមកពីការអន់ថយតម្លៃ ប្រសិនបើមាន ។ ថ្លៃដើមរួមមានចំណាយផ្ទាល់ផ្សេងៗ ដែលបានរួមចំណែកក្នុងការនាំយកទ្រព្យសកម្មនោះទៅកាន់ទីតាំង និងលក្ខខណ្ឌចាំបាច់ ដើម្បីឱ្យវាមានសមត្ថភាពប្រតិបត្តិការទៅតាមបំណងរបស់គណៈគ្រប់គ្រង ។

ចំណាយក្នុងការផ្លាស់ប្តូរគ្រឿងបន្លាស់នៃទ្រព្យសម្បត្តិ និងបរិក្ខារណាមួយ ត្រូវបានកត់ត្រាបន្ថែម ទៅក្នុងតម្លៃយោងនៃទ្រព្យសកម្មនោះ នៅពេលដែលប្រតិបត្តិការនេះកើតឡើង ហើយប្រសិនបើក្រុមហ៊ុនរំពឹងថាការផ្លាស់ប្តូរគ្រឿងបន្លាស់នេះ នឹងផ្តល់អត្ថប្រយោជន៍បន្ថែមនាពេលអនាគតដល់ក្រុមហ៊ុន ។ តម្លៃយោងរបស់គ្រឿងបន្លាស់ដែលបានផ្លាស់ប្តូរនឹងមិនត្រូវបានកត់ត្រាទេ ។ រាល់ចំណាយលើការជួសជុល និងការថែទាំ ត្រូវបានកត់ត្រាជាបន្ទុកចំណេញ ឬខាត ក្នុងអំឡុងឆ្នាំដែលប្រតិបត្តិការនោះបានកើតឡើង ។

ការធ្វើរំលស់ទៅលើគ្រប់ទ្រព្យសម្បត្តិ និងបរិក្ខារត្រូវបានកត់ត្រាជាបន្ទុកដើម្បីបែងចែកថ្លៃដើមទ្រព្យសកម្ម ដកតម្លៃសំណល់របស់វាលើអាយុកាលប្រើប្រាស់ ប៉ាន់ស្មានដោយគណនាតាមវិធីសាស្រ្តរំលស់ថេរ ។ ការប៉ាន់ស្មានអាយុកាលប្រើប្រាស់របស់ទ្រព្យសកម្ម មានដូចខាងក្រោម ៖

| | |
|---|---|
| ការកែលម្អលើទ្រព្យជួល | ៣ឆ្នាំ |
| គ្រឿងសង្ហារឹម និងបរិក្ខារភ្ជាប់ | ៣ឆ្នាំ |
| បរិក្ខារការិយាល័យ | ៣ឆ្នាំ |
| បរិក្ខារកុំព្យូទ័រ | ៣ឆ្នាំ |
| យានយន្ត | ៥ឆ្នាំ |

ទ្រព្យសកម្មកំពុងដំណើរការ មិនបានធ្វើការរំលស់រហូតដល់ពេលដែលវាអាចប្រើប្រាស់បាន ។

តម្លៃសំណល់របស់ទ្រព្យសកម្ម អាយុកាលប្រើប្រាស់ និងវិធីសាស្រ្តរំលស់ត្រូវបានត្រួតពិនិត្យឡើងវិញ និងកែលម្អ តម្រូវទៅតាមស្ថានភាពសមស្រប ប្រសិនបើមានសញ្ញាណជាក់លាក់ណាមួយ អំពីការប្រែប្រួលគិតចាប់តាំងពីកាលបរិច្ឆេទរាយការណ៍ចុងក្រោយបង្អស់ ។

តម្លៃយោងនៃទ្រព្យសកម្មណាមួយ ដែលលើសពីតម្លៃដែលអាចស្រង់មកវិញបាន វាត្រូវបានកត់ត្រាបន្ថយភ្លាម ឱ្យនៅត្រឹមតម្លៃដែលអាចស្រង់មកវិញបានរបស់វា ។

ចំណេញ និងខាត បណ្តាលពីការលក់ចេញទ្រព្យសម្បត្តិ និងបរិក្ខារណាមួយ ត្រូវបានកំណត់ ដោយការប្រៀបធៀបសាច់ប្រាក់បានពីការលក់ និងតម្លៃយោងនៃទ្រព្យសកម្មនោះ ហើយត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផលលម្អិត ក្នុងគណនី "(ខាត)/ចំណេញផ្សេងៗ-សុទ្ធ" ។

## ២.៧ ទ្រព្យសកម្មអរូបី

ទ្រព្យសកម្មអរូបីដែលរួមមានអាជ្ញាប័ណ្ណ កម្មវិធីកុំព្យូទ័រដែលបានទិញ និងចំណាយពាក់ព័ន្ធផ្សេងៗ ត្រូវបានរាយការណ៍តាមថ្លៃដើមដករំលស់បង្គរ និងការខាតដែលបណ្តាលមកពីការថយចុះតម្លៃ ។ អាជ្ញាប័ណ្ណកម្មវិធីកុំព្យូទ័រដែលបានទិញ ត្រូវបានធ្វើមូលធនកម្មតាមមូលដ្ឋានថ្លៃដើមដែលបានកើតឡើងក្នុងការទិញកម្មវិធីជាក់លាក់នោះមកប្រើប្រាស់ ។ រំលស់ត្រូវបានគណនាដោយប្រើវិធីសាស្រ្តរំលស់ថេរ ដើម្បីបែងចែកថ្លៃដើមនៃកម្មវិធីកុំព្យូទ័រ រយៈពេលប្រើប្រាស់របស់វាក្នុងរយៈពេល៥ឆ្នាំ។

## ២.៨ ការថយចុះតម្លៃនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

ទ្រព្យសកម្មដែលត្រូវធ្វើរំលស់រូបី ឬអរូបី ត្រូវបានគេត្រួតពិនិត្យរៀងរាល់កាលបរិច្ឆេទរាយការណ៍នីមួយៗ ដើម្បីកំណត់ថា តើមានការចង្អុលបង្ហាញអំពីការថយចុះតម្លៃរបស់វាឬទេ ។នៅពេលដែលមានការចង្អុលបង្ហាញថាតម្លៃយោងរបស់ទ្រព្យសកម្មនោះត្រូវបានថយចុះ តម្លៃយោងរបស់ទ្រព្យសកម្ម (ឬ cash generating unit (CGUs) នៃទ្រព្យសកម្មដែលគេចាត់ថ្នាក់) ត្រូវបានប៉ាន់ស្មានរកការថយចុះតម្លៃរបស់វា ។ ការខាតបង់ បណ្តាលមកពីការថយចុះតម្លៃ ត្រូវបានគេកត់ត្រានៅពេលដែលតម្លៃយោងរបស់ទ្រព្យសកម្មនោះ លើសពីចំនួន ដែលនឹងត្រូវយកវិញ ។ ចំនួនដែលអាចយកមកវិញបាន គឺជាតម្លៃណាមួយដែលខ្ពស់ជាងរវាងតម្លៃសមរម្យ នៃទ្រព្យសកម្មនោះដកចំណាយក្នុងការលក់ និងតម្លៃបានពីការប្រើប្រាស់ទ្រព្យសកម្មនោះ ។ ក្នុងការប៉ាន់ស្មានរកការថយចុះតម្លៃទ្រព្យសកម្មទាំងនេះ ត្រូវបានគេបែងចែកជាក្រុមតូចៗ តាមដែលអាចធ្វើទៅបាន (CGUs) ដើម្បីកំណត់ពីលំហូរសាច់ប្រាក់របស់វានីមួយៗ ។

## ២.៩ គណនីត្រូវទូទាត់ផ្សេងៗ

គណនីត្រូវទូទាត់ផ្សេងៗ ត្រូវបានកត់ត្រាជាដំបូង ទៅតាមតម្លៃរបស់ប្រតិបត្តិការ ហើយត្រូវបានវាស់វែងជាបន្តបន្ទាប់ ទៅតាមថ្លៃដើមដករំលស់ដោយប្រើវិធីសាស្រ្តការប្រាក់មានប្រសិទ្ធភាព ។

## ២.១០ សំវិធានធន

សំវិធានធនត្រូវបានកត់ត្រា នៅពេលដែលក្រុមហ៊ុនមានកាតព្វកិច្ចផ្លូវច្បាប់នាពេលបច្ចុប្បន្ន ឬកាតព្វកិច្ច ដែលកើតចេញពីលទ្ធផលនៃព្រឹត្តការណ៍អតីតកាល ដែលទំនងជាតម្រូវឱ្យក្រុមហ៊ុនធ្វើការដោះស្រាយ និងទូទាត់កាតព្វកិច្ចទាំងនោះ ហើយចំនួនទឹកប្រាក់អាចប៉ាន់ស្មាន ដែលគួរឱ្យជឿជាក់បាន ។ ក្រុមហ៊ុនមិនកត់ត្រាសំវិធានធនចំពោះការខាតបង់ពីប្រតិបត្តិការនាពេលអនាគតទេ ។

សំវិធានធនត្រូវបានវាស់វែងតាមតម្លៃបច្ចុប្បន្ន នៃចំណាយដែលរំពឹងថាត្រូវទូទាត់កាតព្វកិច្ចទាំងនោះ ដោយប្រើអត្រាមុនបង់ពន្ធ ដែលឆ្លុះបញ្ចាំងការវាយតម្លៃសមរម្យបច្ចុប្បន្ននៃតម្លៃពេលវេលាទឹកប្រាក់ និងហានិភ័យជាក់លាក់ផ្សេងៗចំពោះកាតព្វកិច្ចនោះ ។ ការកើនឡើងនូវសំវិធានធនពីការិយបរិច្ឆេទមួយ ទៅការិយបរិច្ឆេទមួយត្រូវបានកត់ត្រាជាចំណាយការប្រាក់ ។

## ២.១១ អត្ថប្រយោជន៍បុគ្គលិក

### *ក. មូលនិធិសោធននិវត្តន៍បុគ្គលិក*

ក្រុមហ៊ុនផ្តល់ជូនបុគ្គលិករបស់ខ្លួន នូវមូលនិធិសោធននិវត្តន៍ ដែលជាគម្រោងកំណត់វិភាគទាន ។ មូលនិធិនេះ គឺបានពីវិភាគទានប្រចាំខែដែលត្រូវបានកំណត់ ដោយផ្អែកលើប្រាក់បៀវត្សរ៍ប្រចាំខែរបស់បុគ្គលិកហើយត្រូវបានផ្តល់វិភាគទានពីក្រុមហ៊ុន ចំនួន១០% (២០១៣៖ ១០%) និងវិភាគទានពីបុគ្គលិកចំនួន ៥% (២០១៣៖ ៥%) ។

ចំណាយសម្រាប់មូលនិធិសោធននិវត្តន៍ ត្រូវបានកត់ត្រាជាចំណាយនៅក្នុងរបាយការណ៍លទ្ធផលលម្អិត ។ មូលនិធិនេះ ត្រូវបានរក្សាទុកដោយ

ធនាគារ អេស៊ីលីដា ភីអិលស៊ី ។

មូលនិធិសោធននិវត្តន៍នឹងត្រូវបានបង់ពេញលេញដោយធនាគារអេស៊ីលីដា ភីអិលស៊ី ទៅឱ្យបុគ្គលិក នៅពេលដែលបុគ្គលិកឈប់បម្រើការងារឱ្យក្រុមហ៊ុន ។

### ខ. អត្ថប្រយោជន៍ពេលចូលនិវត្តន៍

ក្រុមហ៊ុនផ្តល់ជូនបុគ្គលិកពេញសិទ្ធិរបស់ខ្លួន នូវគម្រោងអត្ថប្រយោជន៍ពេលចូលនិវត្តន៍ ដែលមិនមានមូលនិធិដាច់ដោយឡែក នៅពេលដែលពួកគាត់ដល់អាយុចូលនិវត្តន៍ ដូចខាងក្រោម៖

- បុគ្គលិកដែលមានអតីតភាពការងារជាមួយក្រុមហ៊ុន ចំនួន១៥ឆ្នាំ ឬលើស ហើយត្រូវដល់អាយុចូលនិវត្តន៍នៅអាយុ៥៨ឆ្នាំចំពោះអ្នកគ្មានជំនាញនិង ៦០ឆ្នាំ ចំពោះអ្នកមានជំនាញនឹងត្រូវទទួលបានអត្ថប្រយោជន៍ពេលចូលនិវត្តន៍ស្មើនឹងប្រាក់បៀវត្សចំនួន១២ខែ នៃប្រាក់បៀវត្សមូលដ្ឋានចុងក្រោយ។
- បុគ្គលិកដែលមានអតីតភាពការងារជាមួយក្រុមហ៊ុន ចំនួន១៥ឆ្នាំ ឬលើស ហើយត្រូវដល់អាយុចូលនិវត្តន៍មុននៅអាយុ៥៥ឆ្នាំ ចំពោះអ្នកគ្មានជំនាញ និង៥៧ឆ្នាំ ចំពោះអ្នកមានជំនាញ នឹងត្រូវទទួលបានអត្ថប្រយោជន៍ពេលចូលនិវត្តន៍ស្មើនឹងប្រាក់បៀវត្សចំនួន៦ខែ នៃប្រាក់បៀវត្សមូលដ្ឋានចុងក្រោយ។

ចំពោះអត្ថប្រយោជន៍ពេលចូលនិវត្តន៍នេះ មិនមានរក្សាទុកក្នុងមូលនិធិដាច់ដោយឡែកទេ ហើយក៏មិនមានការប្រាក់ដែរ ។

## ២.១២ ដើមទុន

ភាគហ៊ុនធម្មតា ត្រូវបានចាត់ថ្នាក់ជាមូលធន ។ ឧបករណ៍មូលធន ត្រូវបានវាស់វែងតាមតម្លៃសមរម្យ នៃសាច់ប្រាក់ ឬធនធានដទៃទៀតដែលបានទទួល ឬត្រូវទទួល ដកនឹងចំណាយផ្ទាល់ផ្សេងៗក្នុងការបោះផ្សាយឧបករណ៍មូលធន ។ ប្រសិនបើ ការទូទាត់ត្រូវបានពន្យារ ហើយតម្លៃពេលវេលានៃទឹកប្រាក់មានចំនួនជាសារវន្ត នោះការវាស់វែងជាបឋមត្រូវបានវាស់វែងតាមមូលដ្ឋានតម្លៃបច្ចុប្បន្ន ។

## ២.១៣ ការទទួលស្គាល់ចំណូល

ចំណូល រួមមានតម្លៃសមរម្យ នៃអត្ថប្រយោជន៍ដែលទទួលបាន ឬត្រូវទទួលពីការផ្តល់សេវាកម្មផ្សេងៗនៅក្នុងដំណើរការអាជីវកម្មធម្មតារបស់ក្រុមហ៊ុន ។

ក្រុមហ៊ុនកត់ត្រាចំណូល នៅពេលដែលចំនួននៃប្រាក់ចំណូលនោះ អាចវាស់វែងបានយ៉ាងគួរឱ្យទុកចិត្ត ហើយវាមានភាពប្រាកដថា អត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគត នឹងកើតមានចំពោះក្រុមហ៊ុន ។ ចំណូលទទួលបានពីសេវាកម្មបណ្តុះបណ្តាល និងសេវាកម្មប្រឹក្សា ត្រូវបានកត់ត្រានៅពេលដែលសេវាកម្មនោះត្រូវបានផ្តល់រួចរាល់ ។

## ២.១៥ ចំណូលបានមកពីជំនួយ

ជំនួយដែលទទួលបានពី Kredittanstalt Fur Wiederaufbau ("KfW") គឺសម្រាប់ផ្គត់ផ្គង់ ក) សម្ភារបណ្តុះបណ្តាល ខ) កម្រៃសេវាប្រឹក្សា និង គ) ការពង្រឹងសមត្ថភាពនិយោជិតក្នុងស្រុករបស់ក្រុមហ៊ុន។ ជំនួយត្រូវបានកត់ត្រាដំបូងជាចំណូល នៅពេលដែលចំណាយបានកើតឡើង។

## ២.១៥ ពន្ធលើប្រាក់ចំណេញ និងពន្ធពន្យារ

បន្ទុកពន្ធសម្រាប់ការិយបរិច្ឆេទរួមមាន៖ ពន្ធលើប្រាក់ចំណេញ និងពន្ធពន្យារ ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផលលម្អិត ។

ពន្ធលើប្រាក់ចំណេញ ត្រូវគណនាតាមមូលដ្ឋានច្បាប់ពន្ធ ដែលបានអនុម័តរួច ឬអនុម័តរួចមួយផ្នែកធំ គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍ ។

